ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

# ផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍ ខ្សាច់លាវ សម្រាប់រយៈពេល ៣ ឆ្នាំ (កក្កដា ២០១៩ - មិថុនា ២០២២)

| | | |
|---|---|---|
| សហគមន៍នេសាទ | ៖ | ខ្សាច់លាវ |
| ភូមិ | ៖ | ខ្សាច់លាវ |
| ឃុំ | ៖ | អូរគ្រៀង |
| ស្រុក | ៖ | សំបូរ |
| ខេត្ត | ៖ | ក្រចេះ |

ខែមករា ឆ្នាំ២០១៩

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

# ផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍
# ខ្សាច់លាវ សម្រាប់រយៈពេល ៣ ឆ្នាំ
# (កក្កដា ២០១៩ - មិថុនា ២០២២)

សហគមន៍នេសាទ ៖ ខ្សាច់លាវ
ភូមិ ៖ ខ្សាច់លាវ
ឃុំ ៖ អូរគ្រៀង
ស្រុក ៖ សំបូរ
ខេត្ត ៖ ក្រចេះ

ខែមករា ឆ្នាំ២០១៩

# មាតិកា


១. ស្ថានភាពទូទៅ ....... ១
២. អំពីប្រជាសាស្ត្រ និងសេដ្ឋកិច្ចសង្គម ....... ២
ក. ប្រជាពលរដ្ឋ ....... ២
ខ. មុខរបរ ....... ២
៣. កន្លែងនេសាទ និងធនធានជលផលដែលមាននៅក្នុងកន្លែងនេសាទ ....... ៣
ក. ទីតាំង ....... ៣
ខ. ដែននេសាទ ....... ៣
គ. តំបន់ដែលមានលទ្ធភាពអាចបង្កើតកន្លែងអភិរក្ស ....... ៤
ឃ. ធនធានជលផល ....... ៤
៤. ការធ្វើនេសាទ ....... ៥
ក. អ្នកនេសាទ ....... ៥
ខ. ឧបករណ៍នេសាទ ....... ៥
គ. ការប៉ាន់ប្រមាណផលនេសាទចាប់បានប្រចាំឆ្នាំ ....... ៦
៥. ផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍ ....... ៦
ក. ទស្សនៈវិស័យ ....... ៦
ខ. គោលបំណងរួម ....... ៦
គ. គោលបំណងជាក់លាក់ ....... ៦
ឃ. ផែនការសកម្មភាពគ្រប់គ្រងកន្លែងនេសាទសហគមន៍ ....... ៦
ឃ.១. ធនធានជលផល និងអេកូឡូស៊ី ....... ៦
ឃ.២. ការគាំទ្រជីវភាពប្រជាពលរដ្ឋ ....... ៨
ឃ.៣. ការគ្រប់គ្រង ....... ១១
ង. ការតាមដាន ត្រួតពិនិត្យ និងវាយតម្លៃ ....... ១៤
ច. យុទ្ធសាស្ត្រ ....... ១៤
តារាងសង្ខេបផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍ខ្សាច់លាវរយៈពេល ៣ ឆ្នាំ (២០១៩-២០២២) ....... ១៦
តារាងកម្មវិធីការងារប្រចាំឆ្នាំ (កក្កដា ២០១៩ - មិថុនា ២០២២) ....... ២២

# ផែនការគ្រប់គ្រង
# កន្លែងនេសាទសហគមន៍

## ១. ស្ថានភាពទូទៅ

សហគមន៍នេសាទខ្សាច់លាវ មានទីតាំងស្ថិតនៅក្នុងភូមិខ្សាច់លាវ ឃុំអូរគ្រៀង ស្រុកសំបូរ ខេត្តក្រចេះ។ សហគមន៍នេសាទខ្សាច់លាវ ត្រូវបានបង្កើតឡើងជាផ្លូវការដោយមហាសន្និបាតកំណើតដំបូងប្រារព្ធធ្វើនៅថ្ងៃទី១៤ ខែវិច្ឆិកា ឆ្នាំ២០១០ និងបានចុះកិច្ចព្រមព្រៀងកន្លែងនេសាទសហគមន៍រវាងនាយខណ្ឌរដ្ឋបាលជលផលក្រចេះ និងប្រធានគណៈកម្មការសហគមន៍នេសាទនៅថ្ងៃទី០២ ខែមិថុនា ឆ្នាំ២០១១។ សហគមន៍នេះត្រូវបានចុះបញ្ជីទទួលស្គាល់ជាផ្លូវការដោយប្រកាសលេខ ៦២៨ ប្រក.កសក ចុះថ្ងៃទី២៦ ខែធ្នូ ឆ្នាំ២០១១ របស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ក្រោមការសម្របសម្រួល និងគាំទ្រផ្នែកបច្ចេកទេសពីអង្គការអុកស្វាមអូស្ត្រាលី និងខណ្ឌរដ្ឋបាលជលផល ក្រចេះ។ ដោយសារគណៈកម្មការផុតអាណត្តិ សហគមន៍នេសាទនេះ បានបោះឆ្នោតជ្រើសរើសគណៈកម្មការសហគមន៍ នេសាទឡើងវិញនៅថ្ងៃទី២៩ ខែតុលា ឆ្នាំ២០១៤ និងបានរៀបចំកិច្ចព្រមព្រៀងកន្លែងនេសាទសហគមន៍ឡើងវិញ រវាងនាយខណ្ឌរដ្ឋបាលជលផល និងប្រធានគណៈកម្មការសហគមន៍នេសាទជាលើកទី២នៅថ្ងៃទី២៧ ខែកញ្ញា ឆ្នាំ២០១៦ ក្រោមការឧបត្ថម្ភគាំទ្របន្តពីអង្គការមូលនិធិសកលសម្រាប់អភិរក្សធនធានធម្មជាតិ (WWF)។ យោងតាមភាពចាំបាច់របស់សហគមន៍នេសាទ គម្រោងគ្រប់គ្រងធនធានទឹកចម្រុះទន្លេមេគង្គ (ដំណាក់កាលទី៣) សមាសភាគទី១ ដែលអនុវត្តដោយខណ្ឌរដ្ឋបាលជលផលក្រចេះ បានសម្របសម្រួលចុះធ្វើបច្ចុប្បន្នភាពបញ្ជីឈ្មោះសមាជិកសហគមន៍ នេសាទនៅថ្ងៃទី២២ ខែសីហា ឆ្នាំ២០១៨ តាមការធ្វើបច្ចុប្បន្នភាពកន្លងទៅថ្មីៗនេះ សមាជិកដែលបានចុះក្នុងបញ្ជីជាផ្លូវការសរុបចំនួន ១៤៥ នាក់ ស្រីមានចំនួន ៧០ នាក់ ក្នុងនោះគ្រួសារសរុបមានចំនួន ៧៧ គ្រួសារ។ គណៈកម្មការសហគមន៍នេសាទមានចំនួន ៩ នាក់ ក្នុងនោះស្រីមានចំនួន ១ នាក់ និងបានជ្រើសរើសជំនួយការជាស្ត្រីចំនួន២រូប ដោយបានរៀបចំជារចនាសម្ព័ន្ធគ្រប់គ្រង និងបែងចែកតួនាទីនិងភារកិច្ចទទួលខុសត្រូវតាមការស្ម័គ្រចិត្ត និងឯកភាពគ្នាក្នុងចំណោមសមាជិកគណៈកម្មការទាំងអស់។

ទន្ទឹមនឹងសមិទ្ធផលដែលសម្រេចបានដូចខាងលើ សហគមន៍នេសាទនៅជួបប្រទះនូវបញ្ហាប្រឈមនានាពាក់ព័ន្ធនឹងធនធានជលផលនិងអេកូឡូស៊ី ជីវភាពប្រជាពលរដ្ឋ និងការគ្រប់គ្រងមានដូចខាងក្រោម៖

- បញ្ហាប្រឈមពាក់ព័ន្ធនឹងធនធានជលផលនិងអេកូឡូស៊ី រួមមានបរិមាណត្រីថយចុះ អន្លង់អភិរក្សកាន់តែរាក់ ទឹកទន្លេកើតស្លែច្រើនធ្វើឱ្យត្រីពុល បាក់ដីច្រាំងទន្លេ
- បញ្ហាប្រឈមពាក់ព័ន្ធនឹងជីវភាពប្រជាពលរដ្ឋ រួមមានកំណើនប្រជាពលរដ្ឋ ខ្វះមុខរបរចិញ្ចឹមជីវិត ដីមិនជក់ទឹកដែលអាចចិញ្ចឹមត្រីបាន និងខ្វះបច្ចេកទេសដាំដំណាំ ចិញ្ចឹមសត្វ និងទុនប្រកបមុខរបរ
- បញ្ហាប្រឈមពាក់ព័ន្ធនឹងការគ្រប់គ្រងរួមមានរបបទឹកមិនទៀងទាត់ដោយសារទំនប់វារីអគ្គិសនី បទល្មើសនេសាទ (ឆក់ត្រី ដាក់មងក្រឡាធំ វាយមងជាក្រុម វាយសន្ទូចច្រើននុយអប់ នេសាទត្រីនៅរដូវត្រីពង) សមាជិកសហគមន៍នេសាទនៅពុំទាន់មានការយល់ដឹង និងការចូលរួមការងារសហគមន៍ឱ្យបានសស្រាក់សស្រាំ មានបទល្មើសនេសាទមកពីអ្នកខាងក្រៅសហគមន៍នេសាទ និងមកលួចធ្វើនេសាទនៅកន្លែងអភិរក្សជាពិសេសនៅពេលយប់ សហគមន៍នេសាទចុះល្បាតមិនទៀងទាត់ (ខ្វះទូក ឧបករណ៍សម្ភារសម្រាប់ល្បាត) មិនទាន់មានទីស្នាក់ការសហគមន៍សម្រាប់ប្រតិបត្តិការ

គណៈកម្មការសហគមន៍នេសាទពុំទាន់មានសមត្ថភាពគ្រប់គ្រាន់ក្នុងការដឹកនាំ សហគមន៍នេសាទនៅតែគិតថាការងារគណៈកម្មការជាការងារបច្ចេកទេស និងជាតួនាទីរបស់បុរស ម្យ៉ាងទៀតសមាជិកសហគមន៍នេសាទពួកគាត់ គិតថាការងារគ្រប់គ្រងធនធានជលផលក្នុងសហគមន៍នេសាទជាការងាររបស់គណៈកម្មការ។ ចំណែកស្ត្រីមានតួនាទីជាអ្នកថែទាំគ្រួសារ ការងារផ្ទះ និងលក់ដូរប៉ុណ្ណោះ ហើយទោះបីស្ត្រីមានការចូលរួមក្នុងកិច្ចប្រជុំនានាមានចំនួនច្រើន ប៉ុន្តែការសម្រេចនៅមានកម្រិត។

## ២. អំពីប្រជាសាស្ត្រ និងសេដ្ឋកិច្ចសង្គម

ក. ប្រជាពលរដ្ឋ

ចំនួនប្រជាពលរដ្ឋសរុបនៅក្នុងសហគមន៍មាន ៥៧៣នាក់ ប្រុស ២៨២នាក់ ស្រី២៩១នាក់ ក្នុងនោះមាន១២៦ គ្រួសារ ជាជនជាតិដើមភាគតិចគួយ៦០% ខ្មែរ៤០%។ ប្រជាពលរដ្ឋក្នុងសហគមន៍ជាអ្នកកាន់សាសនាព្រះពុទ្ធ១០០%។

ប្រជាពលរដ្ឋសរុបក្នុងតំបន់សហគមន៍មានស្ថានភាពដូចខាងក្រោម៖

- ចំនួនស្ត្រីមេម៉ាយមាន ១២ នាក់
- ចំនួនជនពិការមាន ៥ នាក់ ស្រី ១ នាក់
- ចំនួនចាស់ជរាមាន ៧ នាក់ ស្រី ២ នាក់
- ចំនួនកុមារកំព្រាមាន ២ នាក់ ស្រី ២ នាក់
- ចំនួនអ្នកមានជំងឺរ៉ាំរ៉ៃមាន ៥ នាក់ ស្រី ៣ នាក់
- កម្រិតសិក្សាអប់រំរួមមាន អ្នកមិនចេះអក្សរមានចំនួន ១៥% ថ្នាក់បឋមសិក្សាចំនួន ៨០% មធ្យមសិក្សាចំនួន៥%។

ខ. មុខរបរ

មុខរបរសំខាន់ៗរបស់ប្រជាពលរដ្ឋក្នុងសហគមន៍នេះរួមមាន ៖

- ធ្វើនេសាទជាលក្ខណៈគ្រួសារចំនួន ១០០ គ្រួសារ (៧៩%)
- ធ្វើស្រែវស្សាចំនួន ៥៧ គ្រួសារ (៤៥%)
- ដាំបន្លែចំនួន ៥៥ គ្រួសារ
- ធ្វើចំការចំនួន ៤៥ គ្រួសារ
- ធ្វើជាងផ្ទះចំនួន ៤ នាក់
- ធ្វើជាងទូកចំនួន ៤ នាក់
- ធ្វើកម្មករនៅពេលទំនេរពីការងារធ្វើស្រែចំនួន ១០ %
- លក់ដូរចំនួន ១២ គ្រួសារ។

## ៣. កន្លែងនេសាទ និងធនធានជលផលដែលមាននៅក្នុងកន្លែងនេសាទសហគមន៍

### ក. ទីតាំង

កន្លែងនេសាទសហគមន៍ខ្សាច់លាវ ជាទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋ ដែលស្ថិតនៅតាមដងទន្លេមេគង្គលើ មានទំហំ ៨៥៣ ហិកតា និងមាននិយាមការ ដូចមានចែងនៅក្នុងកិច្ចព្រមព្រៀង។

មានព្រំប្រទល់ ៖

- ខាងជើងទល់នឹងកោះនរុង្គ ឃុំបឹងចារ ស្រុកសំបូរ ខេត្តក្រចេះ
- ខាងត្បូងទល់នឹងភូមិឧបសម្ព័នកំពង់ដំរី ឃុំបឹងចារ ស្រុកសំបូរ ខេត្តក្រចេះ
- ខាងកើតទល់នឹងកោះជ្រឹម និងកោះរងាវ ឃុំអូរគ្រៀង ស្រុកសំបូរ ខេត្តក្រចេះ
- ខាងលិចទល់នឹងកោះឥន្ទជ័យ ភូមិឧបសម្ព័នកោះឥន្ទជ័យ ឃុំបឹងចារ ស្រុកសំបូរ ខេត្តក្រចេះ។

### ខ. ដែននេសាទ

កន្លែងនេសាទសហគមន៍ខ្សាច់លាវ ស្ថិតនៅតាមដងទន្លេមេគង្គ ដែលមានព្រៃលិចទឹកដុះរាយនៅតាមមាត់ច្រាំងទន្លេ និងនៅតាមកោះ។ កន្លែងនេសាទសហគមន៍ខ្សាច់លាវ មានអន្លង់ចំនួន៣ ព្រែកចំនួន២ អូរចំនួន១៩ និងកោះចំនួន ៣ គឺ៖

| | | |
|---|---|---|
| - អន្លង់កណ្តុរ១០០ | ទំហំ ១៥១,៧៧ ហិកតា | មានទឹកពេញមួយឆ្នាំ |
| - អន្លង់គ្រែង | ទំហំ ៩៧,៩៣ ហិកតា | មានទឹកពេញមួយឆ្នាំ |
| - អន្លង់សម្រង | ទំហំ ៤ ហិកតា | មានទឹកពេញមួយឆ្នាំ |
| - អូរតាចេង | ទំហំ ១០ម x ១០០ម | មានទឹកពីខែកក្កដា-កញ្ញា |
| - អូរកែង | ទំហំ ១៥ម x ១០០ម | មានទឹកពីខែកក្កដា-កញ្ញា |
| - អូរពោន | ទំហំ ៨ម x ៥០ម | មានទឹកពីខែកក្កដា-កញ្ញា |
| - អូរតាឃី | ទំហំ ២០ម x ១៥០ម | មានទឹកពីខែកក្កដា-កញ្ញា |
| - អូរតាខុន | ទំហំ ២០ម x ១៥០ម | មានទឹកពីខែកក្កដា-កញ្ញា |
| - អូរឫស្សីស្រុក | ទំហំ ៣០ម x ៣០០ម | មានទឹកពីខែកក្កដា-កញ្ញា |
| - អូរតាម៉ៅ | ទំហំ ១៥ម x ៨០ម | មានទឹកពីខែកក្កដា-កញ្ញា |
| - អូរតាណាន | ទំហំ ២០ម x ២០០ម | មានទឹកពីខែកក្កដា-កញ្ញា |
| - អូរតាឡា | ទំហំ ១៥ម x ៦០ម | មានទឹកពីខែកក្កដា-កញ្ញា |
| - អូរតាឃឹម | ទំហំ ៣០ម x ៣០០ម | មានទឹកពីខែកក្កដា-កញ្ញា |
| - អូរថ្មគយ | ទំហំ ១៥ម x ២០០ម | មានទឹកពីខែកក្កដា-កញ្ញា |
| - អូរអន្លង់គ្រែង | ទំហំ ១៥ម x ២៥០ម | មានទឹកពីខែកក្កដា-កញ្ញា |

- អូរអន្លង់សម្រង ទំហំ ១០ម x ១០០ម មានទឹកពីខែកក្កដា-កញ្ញា
- អូរតាឃឹម ទំហំ ១៥ម x ៤០០ម មានទឹកពីខែកក្កដា-កញ្ញា
- អូរខ្សាច់លាវ ទំហំ ១៥ម x ៣៥០ម មានទឹកពីខែកក្កដា-កញ្ញា
- អូរតាយេ ទំហំ ២០ម x ២០០ម មានទឹកពីខែកក្កដា-កញ្ញា
- អូរតាសេង ទំហំ ២៥ម x ២៥០ម មានទឹកពីខែកក្កដា-កញ្ញា
- អូរតានិន ទំហំ ៤០ម x ២.២០០ម មានទឹកពីខែកក្កដា-កញ្ញា
- អូរឆ្មៀល ទំហំ ៦០ម x ៣.៥០០ម មានទឹកពីខែកក្កដា-កញ្ញា
- ព្រែកតារស់ ទំហំ ៦០ម x ២.៥០០ម មានទឹកពីខែកក្កដា-វិច្ឆិកា
- ព្រែកអូររមាំង ទំហំ ៤០ម x ២២០ម មានទឹកពីខែកក្កដា-វិច្ឆិកា
- កោះក្តុល (លិចទឹកនៅរដូវវស្សា)
- កោះជ្រឹម ទំហំ ៣គ.ម x ៦គ.ម
- កោះរងាវ ទំហំ ១០គ.ម x ៤៦គ.ម ។

**គ. តំបន់ដែលមានលទ្ធភាពអាចបង្កើតកន្លែងអភិរក្ស**

អន្លង់កណ្តុរ១០០ (ទំហំ ១៥១,៧៧ហិកតា) និងអន្លង់ត្រែង (ទំហំ៩៧,៩៣ហិកតា) ជាតំបន់ដែលមានសក្តានុពលសម្រាប់អភិរក្សត្រីមេពូជ តាមការសម្រេចរបស់មហាសន្និបាត។

**ឃ. ធនធានជលផល**

**ឃ.១. ប្រភេទត្រី ៖**

ឆ្តោកភ្លើង ឆ្តោកក្តា ឆ្លាំង ត្រសក់ ប្រា គល់រាំង គល់ព្រិច រ៉ស់ ក្អែកពូក រៀល ក្អែកខ្មៅ ប្រាកណ្តុរ ឈ្វាត ក្តី ក្រំ កន្ទួនដៃ ខ្យាក្រហម ខ្យាខ្មៅ តានេល អំបុង ព្រលូង រលកស ឆ្អិន កាហែ ច្រកែង អណ្តែង រមាស ក្លាំងហាយ កែស ពោរ ខ្លា ឆ្ពួញ ខ្នឹង ដំរី កញ្ចុះក្តោង កញ្ចុះជរ កញ្ចុះប៉ាវ៉ា ចង្វារមូល ចង្វារភ្លៀង ស្លឹកឫស្សី បង្កួយ ខ្នាន់ ឆ្លុកដប កំពឹងដូង ឫសចេក ខ្សាន ក្រាញ់ ផ្ទោង ស្លាត ស្រកាក្តាម ព្រួល ប្រម៉ា ក្រិម ពុកមាត់ឆ្មារ ដងដាវ ក្តុក ក្រពត អណ្តាតឆ្កែ កញ្ច្រូក ឆ្តោរ ក្រពាត់ សណ្តាយ ក្រាយ អំពិលទុំ សារិកាកែវ កន្ត្រប់ កន្ត្រង់ប្រេង កំភ្លាញ កន្ធរ ផ្ទក់ ស្នក់ ប៉ាវ៉ា ប៉ាស៊ីអ៊ី រាហូ ត្រចៀកដំរី។

**ឃ.២. ប្រភេទវារីសត្វ ៖**

បង្កង កំពិស អណ្តើក គ្រកួត កន្ធាយ ល្មិច ខ្យង បបែល ពស់ព្រលិត ពស់សម្លាប់កង្កែប អន្ទង់ កង្កែប ក្តាម ខ្ចៅ គ្រុំ ចាក់ច្រែង ហ៊ីង គេ។

**ឃ.៣. ប្រភេទថនិកសត្វទឹក ៖**

ផ្សោតក្បាលត្រឡោក ។

ឃ.៤. ព្រៃលិចទឹក និងរាវរុក្ខជាតិ

ដើមត្រស់ រាំង រ៉ៃ ទន្លា អណ្ដែង អញ្ចែង អញ្ជោ ស្រូល រ៉ៃ ញទឹក ស្ដី ព្រីង ខ្ទឹមទឹក ទ្រយឹងទឹក ឃ្នាទឹក ចេកទុំ វល្លិ៍ល្ពាន វល្លិ៍ត្រដិត ច្រកែងក្ងួយ ស្ពៃទឹក ផ្ទង ក្ដុល ឃ្លេ បន្លាយូន ល្វា ជ្រោយ ស្រូយ ក្របៅ បបុស សង្កែ អន្សែង សណ្ដាន់ ស្បូវ មៀន វល្លិ៍ឡុត គ្រែង ស្លត ក្រ ថ្មោង ព្រីងទឹក។

## ៤. ការធ្វើនេសាទ

ក. អ្នកនេសាទ

- អ្នកនេសាទជាសមាជិកសហគមន៍នេសាទមានចំនួន ១៤៥ នាក់ ស្រី ៧០ នាក់
- អ្នកនេសាទមិនមែនជាសមាជិកសហគមន៍នេសាទក្នុងសហគមន៍មានចំនួន ៦០ នាក់ ស្រី ២០ នាក់
- ប៉ាន់ស្មានអ្នកនេសាទមិនមែនជាសមាជិកដែលមកពីក្រៅសហគមន៍ចំនួន ៧០ នាក់ ស្រី ៣០ នាក់។

ខ. ឧបករណ៍នេសាទ

| ប្រភេទឧបករណ៍ | ឯកតា | ចំនួន | | | ទំហំ ប្រវែង | | | រដូវប្រើប្រាស់ឧបករណ៍នេសាទ |
|---|---|---|---|---|---|---|---|---|
| | | សមាជិក | មិនមែនសមាជិក | អ្នកខាងក្រៅភូមិ | សមាជិក | មិនមែនសមាជិក | អ្នកខាងក្រៅភូមិ | |
| សំណាញ់ | វង់ | ២០ | ១០ | ១៥០ | ប្រវែង៧ម ក្រឡា ០,០១៥ ម-០,១៣ម | ប្រវែង៧ម ក្រឡា ០,០១៥ ម-០,១៣ម | ប្រវែង៧ម ក្រឡា ០,០១៥ ម-០,១៣ម | តុលា-មិថុនា |
| លប | គ្រឿង | ៣៥០ | ១៤០ | ៣៧៥ | មុខ១,២ម បណ្ដោយ ១,៨ ម | មុខ១,២ម បណ្ដោយ ១,៨ ម | មុខ១,២ម បណ្ដោយ ១,៨ ម | មិថុនា-តុលា |
| ចាន់ | គ្រឿង | ៣០ | ៦០ | ០ | មុខ០,៦ម កម្ពស់១,៦ម | មុខ០,៦ម កម្ពស់១,៦ម | | មិថុនា-តុលា |
| សន្ទូចរនង | សាង(៥០ផ្លែ) | ១៨០ | ៩០ | ១៤.០០០ | ផ្លែលេខ ៧-១២ | ផ្លែលេខ ៧-១២ | ផ្លែលេខ ៧-១២ | តុលា-មិថុនា |
| មង | ត្បូង(៨០ម) | ៣៣០ | ៨០ | ៤៩០ | ២,៥-៩សម | ២,៥-៩សម | ២,៥-១៦សម | ពេញ១ឆ្នាំ |

ម = ម៉ែត្រ ស.ម = សង្ទីម៉ែត្រ

ប្រភេទទូកកាណូត

| ប្រភេទទូកកាណូត | ចំនួន | | | ចំណុះ | | | កម្លាំងសេះ | | |
|---|---|---|---|---|---|---|---|---|---|
| | សមាជិក | មិនមែនសមាជិក | អ្នកខាងក្រៅភូមិ | សមាជិក | មិនមែនសមាជិក | អ្នកខាងក្រៅភូមិ | សមាជិក | មិនមែនសមាជិក | អ្នកខាងក្រៅភូមិ |
| ទូកម៉ាស៊ីន | ១៦០ | ៦៥ | ៧០ | ៣០០-៥០០គ.ក | ៣០០-៥០០គ.ក | ៤០០-១.០០០គ.ក | ៦,៥-១៣ | ៦,៥-១៣ | ៨-២៧ |

គ. ការប៉ាន់ប្រមាណផលនេសាទចាប់បានប្រចាំឆ្នាំ

| ប្រភេទផលនេសាទ | បរិមាណផលនេសាទចាប់បានគិតជាមធ្យមក្នុង១គ្រួសារ (គីឡូក្រាម) | | |
|---|---|---|---|
| | រដូវប្រាំង | រដូវវស្សា | សរុបប្រចាំឆ្នាំ |
| ត្រី | ៣៧៩,៣០ | ៥៨៦,៨៦ | ៩១៦,១៦ |

គ.ក្រ = គីឡូក្រាម

## ៥. ផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍

ក. ទស្សនៈវិស័យ

សហគមន៍នេសាទខ្សាច់លាវ មានទស្សនវិស័យរួមចំណែកគ្រប់គ្រងធនធានជលផលប្រកប ដោយសមធម៌ និង ចីរភាព ដើម្បីរួមចំណែកកាត់បន្ថយភាពក្រីក្ររបស់ប្រជាពលរដ្ឋ។

ខ. គោលបំណងរួម

ដើម្បីសម្រេចបាននូវទស្សនវិស័យខាងលើ សហគមន៍នេសាទ មានគោលបំណងរួមដូចខាងក្រោម៖

- ធ្វើឱ្យត្រីមានការកើនឡើង
- បង្កើនប្រាក់ចំណូលដល់សមាជិកសហគមន៍នេសាទ
- បទល្មើសនេសាទមានការថយចុះ។

គ. គោលបំណងជាក់លាក់

- ការពារ និងដាំព្រៃលិចទឹកជាជម្រកត្រីនៅតាមច្រាំងទន្លេ
- បង្កើនជម្រើសមុខរបរចិញ្ចឹមជីវិតដល់សមាជិកសហគមន៍នេសាទ តាមរយៈការចិញ្ចឹមសត្វ ត្រី ដាំបន្លែ អេកូទេសចរ និងមានទីផ្សារសម្រាប់កសិផល
- កាត់បន្ថយបទល្មើសនេសាទ តាមរយៈការផ្សព្វផ្សាយ និងចុះល្បាត ដោយមានកិច្ចសហការជាមួយ អាជ្ញាធរដែនដី និងអ្នកពាក់ព័ន្ធ។

ឃ. ផែនការសកម្មភាពគ្រប់គ្រងកន្លែងនេសាទសហគមន៍

ឃ.១. ធនធានជលផល និងអេកូឡូស៊ី

ឃ.១.១. ផែនការប្រើប្រាស់ឧបករណ៍នេសាទ

ផែនការប្រើប្រាស់ឧបករណ៍នេសាទនៅក្នុងកន្លែងនេសាទសហគមន៍ គឺគិតគូរអំពីប្រភេទដែននេសាទ ប្រភេទ ទំហំ ប្រវែងចំនួនឧបករណ៍នេសាទ ចំនួនអ្នកនេសាទ និងរដូវនេសាទ ត្រូវបានរៀបចំដូចមានក្នុងតារាង៖

| ឈ្មោះ/ទីតាំងកន្លែងនេសាទ | ពេលវេលាធ្វើនេសាទ | ឧបករណ៍នេសាទអនុញ្ញាតឱ្យប្រើ | | | ការប៉ាន់ស្មានថវិកា(ដុល្លារ) |
|---|---|---|---|---|---|
| | | ប្រភេទ | ទំហំ/ប្រវែង | ចំនួន | |
| នៅតាមដងទន្លេមេគង្គ អូរ និងព្រែកទាំងឡាយ នៅខាងក្រៅអន្លង់អភិរក្សសហគមន៍ | មករា ដល់ ធ្នូ | មង | ២,៥-៩សម | ៩០ ត្បូង (១ត្បូង=៨០ម) | ១៥០ (៥០/ឆ្នាំសម្រាប់ការងារផ្សព្វផ្សាយ) |
| | តុលា ដល់ មិថុនា | សំណាញ់ | ប្រវែង៧ម ក្រឡា០,០១៥ម-០,១៣ម | ៤០ វង់ | |
| | | សន្ទូចរនង | ផ្លែលេខ៧-១២ | ៣០០ សាង (១សាង=៥០ផ្លែ) | |
| | មិថុនា ដល់ តុលា | លប | មុខ១,២ម បណ្តោយ១,៨ម | ១០០ លប | |
| | | ចាន់ | មុខ០,៦ម កម្ពស់១,៦ម | ២០ ចាន់ | |

### ឃ.១.២. ផែនការកំណត់ និងរៀបចំកន្លែងអភិរក្សសហគមន៍

ផែនការកំណត់ និងរៀបចំកន្លែងអភិរក្សសហគមន៍ ត្រូវបានរៀបចំខាងក្រោម៖

| ឈ្មោះ/ទីតាំង | ទំហំ (ហិកតា) | ប្រភេទនៃការអភិរក្ស | សកម្មភាព | ការប៉ាន់ស្មានថវិកា (ដុល្លារ) | ថ្ងៃខែឆ្នាំចាប់ផ្តើម | ថ្ងៃខែឆ្នាំបញ្ចប់ |
|---|---|---|---|---|---|---|
| អន្លង់កណ្តុរ១០០ | ១៥១,៧៧ | • ត្រីគ្រប់ប្រភេទ<br>• សត្វទឹកគ្រប់ប្រភេទ<br>• ព្រៃលិចទឹកគ្រប់ប្រភេទ | • ដាក់ពោង និងស្លាកសញ្ញាតាមអន្លង់<br>• តម្លើងផ្ទាំងផ្សព្វផ្សាយអំពីច្បាប់ជលផល និងការអភិរក្ស<br>• លែងកូនត្រីពូជ | • ដាក់ពោង/ស្លាក (៤x២០០=៨០០)<br>• តម្លើងផ្ទាំងផ្សព្វផ្សាយ (២x២០០=៤០០)<br>• លែងកូនត្រីពូជ(៣លើកx៥០០=១.៥០០) | កក្កដា ២០១៩ | មិថុនា ២០២២ |
| អន្លង់គ្រែង | ៩៧,៩៣ | | | | | |

### ឃ.១.៣. ផែនការបោះបង្គោលព្រំប្រទល់ និងផ្ទាំងប៉ាណូផែនទីកន្លែងនេសាទសហគមន៍

ផែនការបោះបង្គោលព្រំប្រទល់ និងផ្ទាំងប៉ាណូផែនទីកន្លែងនេសាទសហគមន៍ ត្រូវបានរៀបចំខាងក្រោម៖

| ឈ្មោះ/ទីតាំង | សកម្មភាព | ចំនួន | ការប៉ាន់ស្មានថវិកា (ដុល្លារ) | ថ្ងៃខែឆ្នាំចាប់ផ្តើម | ថ្ងៃខែឆ្នាំបញ្ចប់ |
|---|---|---|---|---|---|
| • ក្បាលកោះរងាវ<br>• ក្បាលកោះជ្រើម<br>• ក្បាលកោះឥន្ទជ័យ<br>• ក្បែរអន្លង់គ្រែង និងអន្លង់កណ្តុរ១០០ | បោះបង្គោលព្រំប្រទល់កន្លែងនេសាទ (លើគោក) និងពោងស្លាកសញ្ញាសំគាល់ព្រំទល់ (ក្នុងទឹក) | ៤ បង្គោល និង២ពោង (៤x៣០០)+(២x៥០) | ១.៣០០ | សីហា ២០១៩ | ធ្នូ ២០១៩ |
| | រៀបចំ និងលើកផ្ទាំងប៉ាណូផែនទីកន្លែងនេសាទសហគមន៍ | ១ ផ្ទាំង (១x៣០០) | ៣០០ | តុលា ២០១៩ | ធ្នូ ២០១៩ |

### ឃ.១.៤. ផែនការគ្រប់គ្រងព្រៃលិចទឹក

ផែនការគ្រប់គ្រងព្រៃលិចទឹក ត្រូវបានរៀបចំខាងក្រោម៖

| ឈ្មោះ/ទីតាំង | ទំហំ | ប្រភេទកូនឈើដែលត្រូវដាំ និងការពារ | សកម្មភាព | ការប៉ាន់ស្មានថវិកា(ដុល្លារ) | ថ្ងៃខែឆ្នាំចាប់ផ្តើម | ថ្ងៃខែឆ្នាំបញ្ចប់ |
|---|---|---|---|---|---|---|
| ព្រៃលិចទឹកដែលមានស្រាប់ដុះតាមច្រាំងទន្លេ មាត់អូរព្រែក និងកោះ | តាមមាត់ទន្លេ និងកោះក្នុងកន្លែងនៃសាទសហគមន៍ខ្សាច់លាវ | ព្រៃលិចទឹកដែលត្រូវការពាររួមមាន៖ ត្រែង រ៉ៃ គ្រស់ រាំងទន្លា | • ប្រជុំផ្សព្វផ្សាយពីផលប្រយោជន៍ព្រៃលិចទឹក (ស្ត្រីជាគណៈកម្មការសហគមន៍នេសាទចូលរួមផ្សព្វផ្សាយពីផលប្រយោជន៍ព្រៃលិចទឹក ការពារព្រៃលិចទឹក និងដាក់ស្លាកសញ្ញាសម្គាល់)<br>• ការពារព្រៃលិចទឹកដែលមានស្រាប់<br>• ដាក់ស្លាកសញ្ញាហាមកាប់ព្រៃលិចទឹក និងស្លាកសញ្ញា<br>• ដាំព្រៃលិចទឹក<br>• ចុះល្បាតជាប្រចាំ | ៣០០ (៣ឆ្នាំ) | កក្កដា ២០១៩ | មិថុនា ២០២២ |

### ឃ.២. ការគាំទ្រជីវភាពប្រជាពលរដ្ឋ

### ឃ.២.១. ផែនការមុខរបរបង្កើនប្រាក់ចំណូល

ផែនការមុខរបរបង្កើនប្រាក់ចំណូល ត្រូវបានរៀបចំខាងក្រោម៖

| ប្រភេទមុខរបរ | សកម្មភាព | ប្រភេទពូជ | បរិមាណ | ការប៉ាន់ស្មានថវិកា(ដុល្លារ) | ថ្ងៃខែឆ្នាំចាប់ផ្តើម | ថ្ងៃខែឆ្នាំប្រមូលផល |
|---|---|---|---|---|---|---|
| ចិញ្ចឹមគោតាមបច្ចេកទេសជាលក្ខណៈគ្រួសារ | • ជ្រើសរើសគ្រួសារ<br>• បណ្តុះបណ្តាលពីបច្ចេកទេសចិញ្ចឹមគោជាលក្ខណៈគ្រួសារ<br>• ផ្តល់ពូជ និងទិញសម្ភារ<br>• តាមដានត្រួតពិនិត្យ | ក្នុងស្រុក | ៤០គ្រួសារ (២ក្បាល/គ្រួសារ) | ៣០.០០០ | កក្កដា ២០១៩ | មិថុនា ២០២២ |
| ចិញ្ចឹមក្របីតាមបច្ចេកទេសជាលក្ខណៈគ្រួសារ | • ជ្រើសរើសគ្រួសារ<br>• បណ្តុះបណ្តាលពីបច្ចេកទេសចិញ្ចឹមក្របីជាលក្ខណៈគ្រួសារ<br>• ផ្តល់ពូជ និងទិញសម្ភារ | ក្នុងស្រុក | ២០គ្រួសារ (១ក្បាល/គ្រួសារ) | ១៦.០០០ | | |

| | | | | | | |
|---|---|---|---|---|---|---|
| | • តាមដានត្រួតពិនិត្យ | | | | | |
| ចិញ្ចឹមទាកាបនិងទាកាប៉ាតាមបច្ចេកទេសជាលក្ខណៈគ្រួសារ | • ជ្រើសរើសគ្រួសារ<br>• បណ្តុះបណ្តាលពីបច្ចេកទេសចិញ្ចឹមទាជាលក្ខណៈគ្រួសារ<br>• ផ្តល់ពូជ និងទិញសម្ភារ<br>• តាមដានត្រួតពិនិត្យ | ក្នុងស្រុក | ២០គ្រួសារ (២០ក្បាល/គ្រួសារ) | ៤.០០០ | | |
| ចិញ្ចឹមជ្រូកតាមបច្ចេកទេសជាលក្ខណៈគ្រួសារ | • ជ្រើសរើសគ្រួសារ<br>• បណ្តុះបណ្តាលបច្ចេកទេសចិញ្ចឹមជ្រូកជាលក្ខណៈគ្រួសារ<br>• ផ្តល់ពូជ និងទិញសម្ភារ<br>• តាមដានត្រួតពិនិត្យ | ក្នុងស្រុក | ២០ គ្រួសារ (៣ក្បាល/គ្រួសារ) | ៣.០០០ | | |
| បណ្តុះផ្សិត | • ជ្រើសរើសគ្រួសារកសិករស្ម័គ្រចិត្ត<br>• បណ្តុះបណ្តាលបច្ចេកទេសបណ្តុះផ្សិត និងធ្វើមេផ្សិត<br>• អនុវត្តផ្ទាល់<br>• តាមដានត្រួតពិនិត្យ | ផ្សិតចំបើង ផ្សិតអំបោះ | ៥ គ្រួសារ | ៥០០ | | |

### ឃ.២.២. ផែនការអភិវឌ្ឍន៍វារីវប្បកម្ម

ផែនការអភិវឌ្ឍន៍វារីវប្បកម្មត្រូវបានរៀបចំខាងក្រោម ៖

| ប្រភេទវារីវប្បកម្ម | សកម្មភាព | ចំនួន | ប្រភេទ | បរិមាណ | ការប៉ាន់ស្មានថវិកា(ដុល្លារ) | ខែ/ឆ្នាំ | |
|---|---|---|---|---|---|---|---|
| | | | | | | ចាប់ផ្តើម | ប្រមូលផល |
| ចិញ្ចឹមត្រីអណ្តែងក្នុងអាងតាមបច្ចេកទេសជាលក្ខណៈគ្រួសារ | • ជ្រើសរើសកសិករស្ម័គ្រចិត្ត<br>• បណ្តុះបណ្តាលបច្ចេកទេសចិញ្ចឹមត្រីអណ្តែងជាលក្ខណៈគ្រួសារ<br>• រៀបចំស្រះចិញ្ចឹមត្រី<br>• ផ្តល់កូនត្រី<br>• តាមដានត្រួតពិនិត្យ | អាងស៊ីម៉ង់ត៍ទំហំ៦មx៦ម (៤អាង/គ្រួសារ) | ត្រីអណ្តែង (១៥០០ កូន/១ អាង) | ៥គ្រួសារx ២.០០០ | ១០.០០០ | កក្កដា ២០១៩ | មិថុនា ២០២២ |

### ឃ.២.៣. ផែនការរៀបចំ និងពង្រឹងក្រុមសន្សំប្រាក់

ផែនការរៀបចំ និងពង្រឹងក្រុមសន្សំប្រាក់ ត្រូវបានរៀបចំខាងក្រោម

| ប្រភេទមុខរបរ | សកម្មភាព | ការប៉ាន់ស្មានថវិកា(ដុល្លារ) | ថ្ងៃខែឆ្នាំចាប់ផ្ដើម | ថ្ងៃខែឆ្នាំបញ្ចប់ |
|---|---|---|---|---|
| បង្កើតក្រុមសន្សំប្រាក់១ក្រុម | • ផ្សព្វផ្សាយទស្សនទានក្រុមសន្សំដល់សហគមន៍<br>• ជ្រើសរើសអ្នកទទួលផល<br>• បោះឆ្នោតជ្រើសរើសប្រធានក្រុម<br>• បង្កើតគោលការណ៍ និងបទបញ្ជាផ្ទៃក្នុង<br>• ផ្ដល់ទុនដល់ក្រុម<br>• តាមដាន និងត្រួតពិនិត្យ | ៣០០ | កក្កដា ២០១៩ | មិថុនា ២០២២ |
| ពង្រឹងក្រុមសន្សំប្រាក់ដែលមានស្រាប់១ក្រុម | • ផ្សព្វផ្សាយទស្សនទានក្រុមសន្សំដល់សហគមន៍<br>• ជ្រើសរើសសមាជិកអ្នកទទួលផលបន្ថែម<br>• ត្រួតពិនិត្យ និងកែលម្អគោលការណ៍ និងបទបញ្ជាផ្ទៃក្នុង<br>• ផ្ដល់ទុនបន្ថែមដល់ក្រុម<br>• តាមដាន និងត្រួតពិនិត្យ | ១០០ | | |

### ឃ.២.៤. ផែនការសេវាសហគមន៍ និងហេដ្ឋារចនាសម្ព័ន្ធខ្នាតតូច

ផែនការសេវាសហគមន៍ និងហេដ្ឋារចនាសម្ព័ន្ធខ្នាតតូច ត្រូវបានរៀបចំខាងក្រោម ៖

| សកម្មភាព | ចំនួន | ការប៉ាន់ស្មានថវិកា (ដុល្លារ) | ថ្ងៃខែឆ្នាំចាប់ផ្ដើម | ថ្ងៃខែឆ្នាំបញ្ចប់ |
|---|---|---|---|---|
| ជួសជុលស្ពានឈើប្រវែង១៥ម៉ែត្រក្នុងភូមិ | ១ | ៧.៥០០ | កក្កដា ២០១៩ | មិថុនា ២០២២ |
| សាងសង់លូបង្ហូរទឹកកាត់ផ្លូវ និងចាក់ដីលើលូ | ២កន្លែង | ៧.០០០ | | |
| ជួសជុលផ្លូវលំក្នុងភូមិប្រវែង១,៥គីឡូម៉ែត ទទឹង៧ម៉ែត្រ | ១ខ្សែ | ១៥.០០០ | | |
| សាងសង់បង្គន់អនាម័យបន្ថែម | ៥០ បង្គន់ | ១០.០០០ | | |

### ឃ.២.៥. ផែនការពង្រឹងសកម្មភាពសហគមន៍នេសាទទេសចរណ៍ធម្មជាតិ

ផែនការពង្រឹងសកម្មភាពសហគមន៍នេសាទទេសចរណ៍ធម្មជាតិ ត្រូវបានរៀបចំខាងក្រោម ៖

| សកម្មភាព | ចំនួន | ការប៉ាន់ស្មានថវិកា(ដុល្លារ) | ថ្ងៃខែឆ្នាំចាប់ផ្ដើម | ថ្ងៃខែឆ្នាំបញ្ចប់ |
|---|---|---|---|---|
| សិក្សាកន្លែងដែលអាចបង្កើតជាតំបន់សហគមន៍នេសាទទេសចរណ៍ធម្មជាតិគឺ អន្លង់គ្រែង និង ក្បាលកោះជ្រឹម | ២ដង | ២០០ | កក្កដា ២០១៩ | ធ្នូ ២០១៩ |
| រៀបចំវគ្គបណ្ដុះបណ្ដាលអំពីបដិសណ្ឋារកិច្ច | ៣វគ្គ (១វគ្គ/ឆ្នាំ) | ១៥០ | កក្កដា ២០១៩ | មិថុនា ២០២២ |
| តម្លើងផ្ទាំងផ្សព្វផ្សាយសកម្មភាពសហគមន៍នេសាទទេសចរណ៍ធម្មជាតិ | ១ ផ្ទាំង | ៣០០ | មករា ២០២០ | មករា ២០២០ |

### ឃ.៣. ការគ្រប់គ្រង

#### ឃ.៣.១. ផែនការសកម្មភាពចុះល្បាតទប់ស្កាត់បទល្មើស

ផែនការសកម្មភាពចុះល្បាតទប់ស្កាត់បទល្មើស ត្រូវបានរៀបចំខាងក្រោម ៖

| សកម្មភាព | តម្រូវការសម្ភារ | ចំនួន | ការប៉ាន់ស្មានថវិកា (ដុល្លារ) | ថ្ងៃខែឆ្នាំចាប់ផ្តើម | ថ្ងៃខែឆ្នាំបញ្ចប់ |
|---|---|---|---|---|---|
| សហគមន៍ចុះល្បាតដោយខ្លួនឯង (រដូវវស្សា) | | ៤ដង/១ខែ (៤ដងx៦ខែ x៣x៥០) | ៣.៦០០ | កក្កដា ២០១៩ | មិថុនា ២០២២ |
| ចុះល្បាតដោយសហការជាមួយអាជ្ញាធរមូលដ្ឋានដើម្បីទប់ស្កាត់បទល្មើសមកពីក្រៅ (រដូវប្រាំង) | | ៤ដង/១ខែ (៤ដងx៦ខែ x៣x៥០) | ៣.៦០០ | វិច្ឆិកា ២០១៩ | មេសា ២០២២ |
| ផ្តល់សម្ភារល្បាត (១ ឈុត) | អាវពោង | ១៨ អាវ | ១.០០០ | កក្កដា ២០១៩ | កញ្ញា ២០១៩ |
| | អាវភ្លៀង | ១៨ អាវ | | | |
| | គោមបំភ្លឺពាក់ក្បាល | ៩ គោម | | | |
| | វិទ្យុទាក់ទង | ៩ គ្រឿង | | | |
| | កែវយឹត | ២ គ្រឿង | | | |
| | ម៉ាស៊ីនថត | ២ គ្រឿង | | | |
| | អង្រឹងមានមុង | ១៨ | | | |
| | តង់គ្របទូក៤មx៦ម | ១ | | | |
| | សម្ភារត្រួតពិនិត្យទឹក | ១គ្រឿង | | | |
| | ស្លាបចក្រ | ១៥គ្រឿង | | | |
| | សោរសម្រាប់ជួសជុលទូក | ១សម្រាប់ | | | |
| | សោរច្រវាក់ចាក់ទូក | ២ | | | |
| | អាវយឺត | ១៨ | | | |
| ទិញទូកស្នាច់ និងម៉ាស៊ីន | | ២ គ្រឿង | ៣.០០០ | | |
| ប្រេងសម្រាប់ល្បាត | | ១២០លីត្រ/ខែx៣៦ខែ | ៤.៣២០ | តុលា ២០១៩ | មិថុនា ២០២២ |
| សេវាជួសជុលនិងថែទាំទូក និងម៉ាស៊ីន | | ២ដង/ឆ្នាំ (៦ដងx១០០) | ៦០០ | | |
| សាងសង់ទីស្នាក់ការសហគមន៍ | | ១ កន្លែង | ៣.០០០ | កក្កដា ២០១៩ | កញ្ញា ២០១៩ |

### ឃ.៣.២. ផែនការពង្រឹងគណៈកម្មការសហគមន៍នេសាទ

ផែនការពង្រឹងគណៈកម្មការសហគមន៍នេសាទ ត្រូវបានរៀបចំខាងក្រោម៖

| សកម្មភាព | ចំនួន | ការប៉ាន់ស្មានថវិកា (ដុល្លារ) | ថ្ងៃខែឆ្នាំចាប់ផ្ដើម | ថ្ងៃខែឆ្នាំបញ្ចប់ |
|---|---|---|---|---|
| ប្រជុំប្រចាំខែរបស់គណៈកម្មការសហគមន៍នេសាទ | ១ដង/១ខែ (៣៦ដងx១០) | ៣៦០ | កក្កដា ២០១៩ | មិថុនា ២០២២ |
| ចូលរួមប្រជុំប្រចាំខែជាមួយក្រុមប្រឹក្សាឃុំ | ១ដង/១ខែ (៣៦ដងx១០) | ៣៦០ | | |
| បណ្តុះបណ្តាលអំពីរបៀបធ្វើកំណត់ហេតុ សរសេរលិខិតរដ្ឋបាល របាយការណ៍ និងការរៀបចំទុកដាក់ឯកសារ | ១លើក/១ឆ្នាំ(៣លើកx២០) | ៦០ | | |
| បណ្តុះបណ្តាលអំពីការដោះស្រាយទំនាស់ | ១លើក/១ឆ្នាំ (៣លើកx២០) | ៦០ | | |
| បណ្តុះបណ្តាលអំពីភាពជាអ្នកដឹកនាំ | ១លើក/១ឆ្នាំ (៣លើកx២០) | ៦០ | | |
| បណ្តុះបណ្តាលអំពីការរៀបចំផែនការសកម្មភាពការងារ | ១លើក/១ឆ្នាំ (៣លើកx២០) | ៦០ | | |
| បណ្តុះបណ្តាលអំពីការកត់ត្រាចំណាយចំណូល | ១លើក/១ឆ្នាំ (៣លើកx២០) | ៦០ | | |
| បណ្តុះបណ្តាលអំពីការសរសេរសំណើថវិកា | ១លើក/១ឆ្នាំ (៣លើកx២០) | ៦០ | | |

### ឃ.៣.៣. ផែនការបង្កើនការយល់ដឹងដល់សមាជិកសហគមន៍នេសាទ

ផែនការបង្កើនការយល់ដឹងដល់សមាជិកសហគមន៍នេសាទ ត្រូវបានរៀបចំខាងក្រោម៖

| ផែនការ | សកម្មភាព | ចំនួន | ការប៉ាន់ស្មានថវិកា (ដុល្លារ) | ថ្ងៃខែឆ្នាំចាប់ផ្ដើម | ថ្ងៃខែឆ្នាំបញ្ចប់ |
|---|---|---|---|---|---|
| បង្កើនការយល់ដឹងដល់សមាជិកសហគមន៍នេសាទ | ផ្សព្វផ្សាយលក្ខន្តិកៈ និងបទបញ្ជាផ្ទៃក្នុងសហគមន៍នេសាទ | ២ដង/ឆ្នាំ (៦ដងx២៥) | ១៥០ | កក្កដា ២០១៩ | មិថុនា ២០២២ |
| | ផ្សព្វផ្សាយកិច្ចព្រមព្រៀងកន្លែងនេសាទសហគមន៍ | ១ដង/ឆ្នាំ (៣ដងx២៥) | ៧៥ | | |
| | ផ្សព្វផ្សាយដែននេសាទ និងកន្លែងអភិរក្សរបស់សហគមន៍ | ១ដង/ឆ្នាំ (៣ដងx២៥) | ៧៥ | | |
| | ផ្សព្វផ្សាយពីការប្រមូលប្រាក់បដិភាគ | ១ដង/ឆ្នាំ (៣ដងx១០) | ៣០ | | |
| | ផ្សព្វផ្សាយច្បាប់ជលផល និងបទដ្ឋានគតិ | ១ដង/ឆ្នាំ | ៧៥ | | |

| | | | | | |
|---|---|---|---|---|---|
| | យុត្តិពាក់ព័ន្ធ | (៣ដង x ២៥) | | | |
| | យុទ្ធនាការផ្សព្វផ្សាយការយល់ដឹងអំពីសារប្រយោជន៍ធនធានជលផល | ១ដង/ឆ្នាំ (៣ដង x ១០០) | ៣០០ | | |
| | ប្រជុំផ្សព្វផ្សាយអំពីតួនាទីរបស់បុរស ស្ត្រី ក្នុងសហគមន៍នេសាទ និងការងារផ្ទះ: សមភាព និងសមធម៌យេនឌ័រ | ១ដង/ឆ្នាំ (៣ដង x ២៥) | ៧៥ | | |

## ឃ.៣.៤. ការផ្សព្វផ្សាយផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍

ការផ្សព្វផ្សាយផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍ ត្រូវបានរៀបចំខាងក្រោម៖

| សកម្មភាព | ការប៉ាន់ស្មានថវិកា(ដុល្លារ) | ថ្ងៃខែឆ្នាំចាប់ផ្តើម | ថ្ងៃខែឆ្នាំបញ្ចប់ | អ្នកទទួលខុសត្រូវ |
|---|---|---|---|---|
| ផ្សព្វផ្សាយផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍ទៅសមាជិកសហគមន៍តាមរយៈ បុណ្យទាន មហាសន្និបាតប្រចាំឆ្នាំ | ១៥០ (៣លើក x ៥០) | កក្កដា ២០១៩ | មិថុនា ២០២២ | គណៈកម្មាការសហគមន៍នេសាទ |
| បញ្ចូលផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍ទៅក្នុងកម្មវិធីវិនិយោគឃុំ | ៣០ (៣លើក x ១០) | | | គណៈកម្មាការសហគមន៍នេសាទ |

## ឃ.៣.៥. ផែនការថវិកាទ្រទ្រង់សម្រាប់អភិវឌ្ឍន៍សហគមន៍

ផែនការថវិកាទ្រទ្រង់សម្រាប់អភិវឌ្ឍន៍សហគមន៍ ត្រូវបានរៀបចំខាងក្រោម ៖

| ប្រភេទប្រាក់ចំណូល | សកម្មភាព | ថ្ងៃខែឆ្នាំចាប់ផ្តើម | ថ្ងៃខែឆ្នាំបញ្ចប់ | ចំណូលសរុប (ដុល្លារ) | ផ្សេងៗ |
|---|---|---|---|---|---|
| ភាគទានពីសមាជិកសហគមន៍ | ចុះប្រមូលប្រាក់សមាជិកភាព | កក្កដា ២០១៩ | មិថុនា ២០២២ | ១៨១,២៥ | ៥.០០០រៀល/នាក់ (១៤៥នាក់) |
| ភាគទានប្រចាំឆ្នាំ | ចុះប្រមូលប្រាក់ភាគទានប្រចាំឆ្នាំ | | | ១៦៣,១២ | ១.៥០០រៀល/គ្រួសារ ក្នុងមួយឆ្នាំ (១៤៥នាក់) |
| ប្រាក់ចំណូលពីប្រភពផ្សេងៗ (អំណោយពីរាជរដ្ឋាភិបាល អំណោយពីសប្បុរសជន ជំនួយពីអង្គការជាតិ និងអង្គការដៃគូ) | • ទំនាក់ទំនងជាមួយស្ថាប័នជលផល<br>• សរសេរគម្រោងស្នើសុំពីអង្គការដៃគូ | | | ១៣០.៨៣៥,៦៣ | សរសេរគម្រោងចំណាយថវិកា ៥០០ដុល្លារ |
| សរុប | | | | ១៣១.១៨០ | |

ង. ការតាមដាន ត្រួតពិនិត្យ និងវាយតម្លៃ

ការតាមដាន ត្រួតពិនិត្យ និងវាយតម្លៃ ត្រូវបានរៀបចំខាងក្រោម៖

| សកម្មភាព | ការប៉ាន់ស្មានថវិកា(ដុល្លារ) | ថ្ងៃខែឆ្នាំចាប់ផ្តើម | ថ្ងៃខែឆ្នាំបញ្ចប់ | អ្នកទទួលខុសត្រូវ |
|---|---|---|---|---|
| ប្រជុំផ្ទៃក្នុង ប្រចាំត្រីមាសរបស់គណៈកម្មការសហគមន៍នេសាទ | ១២០<br>(១២ដងx១០) | កក្កដា<br>២០១៩ | មិថុនា<br>២០២២ | គណៈកម្មការសហគមន៍នេសាទ |
| រៀបចំមហាសន្និបាតសហគមន៍ប្រចាំឆ្នាំ ដោយមានការចូលរួមពីស្ត្រីជនជាតិដើមភាគតិច និងជនជាតិភាគតិច | ៦០០<br>(៣ដងx២០០) | | | គណៈកម្មការសហគមន៍នេសាទ |

ច. យុទ្ធសាស្ត្រ

ដើម្បីអនុវត្តផែនការឱ្យទទួលបានជោគជ័យ យុទ្ធសាស្ត្រមួយចំនួនត្រូវបានរៀបចំដូចខាងក្រោម៖

- បង្កើតគណៈកម្មការសម្រាប់អនុវត្តតាមដានត្រួតពិនិត្យ និងវាយតម្លៃការអនុវត្តផែនការរួមមានសមាជិកគណៈកម្មការសហគមន៍នេសាទ ចាស់ទុំ សមាជិកសហគមន៍នេសាទ ដែលមានបទពិសោធន៍ និងចំណេះដឹងល្អ ជាពិសេសអំពីបញ្ហានេសាទ
- ស្នើសុំជំនួយបច្ចេកទេសពីរដ្ឋបាលជលផលមានសមត្ថកិច្ច ដើម្បីជួយផ្តល់យោបល់លើផែនការណា ដែលទាក់ទងនឹងបច្ចេកទេសជលផលដូចជាការធ្វើផែនការកន្លែងអភិរក្សត្រីមេពូជ ការរៀបចំកន្លែងអភិរក្សព្រៃលិចទឹក កន្លែងអភិរក្សជីវៈចម្រុះ ការស្តារព្រែក ការកំណត់ឧបករណ៍នេសាទ ការចិញ្ចឹមត្រី និងការរកថវិកាទ្រទ្រង់ជាដើម
- រៀបចំយុទ្ធសាស្ត្រទំនាក់ទំនងជាមួយស្ថាប័នជំនាញ អង្គការដៃគូ គម្រោង និងម្ចាស់ជំនួយ ដើម្បីទទួលបានការឧបត្ថម្ភគាំទ្រ និងថវិកាសម្រាប់ដំណើរការអនុវត្តផែនការ
- រៀបចំកម្មវិធីអនុវត្តផែនការតាមដំណាក់កាលនីមួយៗឱ្យបានជាក់លាក់
- ទាក់ទងជាមួយរដ្ឋបាលជលផល ដើម្បីសុំការគាំទ្រថវិកានិងជួយរកដៃគូសម្រាប់ទ្រទ្រង់ផែនការគ្រប់គ្រងសហគមន៍នេសាទ
- ផ្សព្វផ្សាយផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍ ដល់សមាជិកសហគមន៍នេសាទ និងអ្នកពាក់ព័ន្ធសំខាន់ៗ ដើម្បីជំរុញការចូលរួម និងគាំទ្រដល់ការអនុវត្តផែនការគ្រប់គ្រងនេះ
- កៀរគរការចូលរួមចំណែករបស់សមាជិកសហគមន៍នេសាទ
- រៀបចំវិធានការចំពោះអ្នកនេសាទមកពីក្រៅសហគមន៍
- ពង្រឹងសមត្ថភាពបច្ចេកទេស និងគ្រប់គ្រងរបស់គណៈកម្មការសហគមន៍នេសាទ
- ចងក្រងក្រុមអ្នកនេសាទទៅតាមប្រភេទឧបករណ៍នេសាទដើម្បីចូលរួមអនុវត្តផែនការ

- បញ្ចូលផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍ទៅក្នុងផែនការអភិវឌ្ឍន៍ និងកម្មវិធីវិនិយោគឃុំ
- ជ្រើសរើសស្ត្រីមេគ្រួសារ ជាសមាជិកចំនួនយ៉ាងតិច៧% ចូលរួមក្នុងសកម្មភាពទ្រទ្រង់ជីវភាពរស់នៅ
- អញ្ជើញស្ត្រីជាសមាជិកសហគមន៍នេសាទចូលរួមយ៉ាងតិច ៤០% ក្នុងការបណ្តុះបណ្តាល សិក្ខាសាលា និងសកម្មភាព ទ្រទ្រង់ជីវភាពរស់នៅ និងវារីវប្បកម្ម
- កម្មករគ្មានជំនាញជាស្ត្រីជាសមាជិកសហគមន៍នេសាទ៤០%ចូលរួមសកម្មភាពហេដ្ឋារចនាសម្ព័ន្ធខ្នាតតូច
- អញ្ជើញស្ត្រីមេគ្រួសារ ស្ត្រីជនជាតិដើមភាគតិច និងជនជាតិភាគតិចជាសមាជិកសហគមន៍នេសាទ ចូលរួមប្រជុំ និងចូលរួមសកម្មភាពនានា និងចូលជាគណៈកម្មការរបស់សហគមន៍នេសាទ
- ជ្រើសរើសស្ត្រីជាសមាជិកសហគមន៍នេសាទ ៥០% ចូលរួមក្នុងសកម្មភាពគាំទ្រជីវភាព
- ផ្តល់ឱកាសស្ត្រី៥០% ជាសមាជិកសហគមន៍នេសាទចូលរួមក្នុងសកម្មភាពគាំទ្រជីវភាព និងទទួលផលប្រយោជន៍ពីគម្រោងក្នុងនោះស្ត្រីជាមេគ្រួសារ៧%
- លើកទឹកចិត្តស្ត្រីជាគណៈកម្មាការចូលរួមក្នុងការសម្រេចចិត្តនានា
- លើកទឹកចិត្តស្ត្រីជាគណៈកម្មាការមិនបោះបង់ចោលការងារ
- រៀបចំការប្រជុំឱ្យសមស្របនឹងពេលវេលារបស់ស្ត្រី ដែលមានលទ្ធភាពចូលរួម
- ជំរុញឱ្យមានស្ត្រីយ៉ាងតិច២៥% ជាសមាជិកគណៈកម្មាការសហគមន៍នេសាទ។

## តារាងសង្ខេបផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍ខ្សាច់ឈាទរយៈពេល ៣ ឆ្នាំ (កក្កដា ២០១៩ - មិថុនា ២០២១)

| ប្រភេទផែនការ | សកម្មភាព | លទ្ធផលរំពឹងទុក | ការប៉ាន់ស្មានថវិកា(ដុល្លារ) | ប្រភពថវិកា | ពេលចាប់ផ្តើម | ពេលបញ្ចប់ | ផ្សេងៗ (ដុល្លារ) |
|---|---|---|---|---|---|---|---|
| ឃ.១. ធនធានជលផល និងអេកូឡូស៊ី | | | | | | | |
| ឃ.១.១. ផែនការប្រើប្រាស់ឧបករណ៍នេសាទ | ផ្សព្វផ្សាយពីប្រភេទឧបករណ៍នេសាទដែលអនុញ្ញាត ទំហំ ពេលវេលា និងទីកន្លែងនេសាទនិងប្រភេទឧបករណ៍នេសាទហាមឃាត់ | ផែនការប្រើប្រាស់ឧបករណ៍នេសាទត្រូវបានផ្សព្វផ្សាយ ២ដង ក្នុង០១ឆ្នាំ (រដូវបិទ និងបើកនេសាទ) | ១៥០ (៥០/១ឆ្នាំ) | អង្គការដៃគូ រដ្ឋបាលជលផល ថវិកាសហគមន៍ | កក្កដា ២០១៩ | មិថុនា ២០២២ | |
| ឃ.១.២. ផែនការកំណត់ និងរៀបចំកន្លែងអភិរក្សសហគមន៍ | ដាក់ពោង និងស្លាកសញ្ញាសំគាល់កន្លែងអភិរក្ស | ពោង និងស្លាកសញ្ញាសំគាល់កន្លែងអភិរក្សចំនួន ៤ ស្លាកត្រូវបានតំឡើង | ៨០០ | អង្គការដៃគូ រដ្ឋបាលជលផល | កក្កដា ២០១៩ | ធ្នូ ២០១៩ | |
| | តម្លើងផ្ទាំងផ្សព្វផ្សាយអំពីច្បាប់ជលផល និងការអភិរក្ស | ផ្ទាំងផ្សព្វផ្សាយអំពីច្បាប់ជលផល និងការអភិរក្សចំនួន ២ ផ្ទាំងត្រូវបានតំលើង | ៤០០ | | កក្កដា ២០១៩ | ធ្នូ ២០១៩ | |
| | លែងកូនត្រីពូជ | កូនត្រីពូជរួមមាន៖ ត្រីខ្លា ត្រីឆ្ពិន ត្រីប្រា ត្រីខ្យា ត្រីឆ្កោក ត្រីគល់រាំង ត្រីក្រសក់ ត្រូវបានលែងចូលក្នុងអន្លង់ | ១.៥០០ (៥០០/១ឆ្នាំ) | | កក្កដា ២០១៩ | មិថុនា ២០២២ | |
| ឃ.១.៣. ផែនការបោះបង្គោលព្រំប្រទល់ និងផ្ទាំងប៉ាណូផែនទីកន្លែងនេសាទសហគមន៍ | បោះបង្គោលព្រំប្រទល់កន្លែងនេសាទ (លើគោក) និងពោងស្លាកសញ្ញាសំគាល់ព្រំប្រទល់ (ក្នុងទឹក) | ៤ បង្គោលបោះលើគោក ២ ពោងដាក់ក្នុងទឹក (តាមអន្លង់) | ១.៣០០ | អង្គការដៃគូ រដ្ឋបាលជលផល | សីហា ២០១៩ | ធ្នូ ២០១៩ | |
| | រៀបចំ និងលើកផ្ទាំងប៉ាណូផែនទីកន្លែងនេសាទសហគមន៍ | ផ្ទាំងប៉ាណូផែនទីកន្លែងនេសាទសហគមន៍១ផ្ទាំងត្រូវបានតម្លើង | ៣០០ | | តុលា ២០១៩ | ធ្នូ ២០១៩ | |

| ប្រភេទផែនការ | សកម្មភាព | លទ្ធផលរំពឹងទុក | ការប៉ាន់ស្មានថវិកា(ដុល្លារ) | ប្រភពថវិកា | ពេលចាប់ផ្តើម | ពេលបញ្ចប់ | ផ្សេងៗ (ដុល្លារ) |
|---|---|---|---|---|---|---|---|
| ឃ.១.៤. ផែនការគ្រប់គ្រងព្រៃលិចទឹក | ដាំព្រៃលិចទឹកតាមច្រាំងទន្លេ មាត់អូរ និងនៅតាមកោះចាប់ពីដើមភូមិដល់ចុងភូមិ | ព្រៃលិចទឹកដែលត្រូវការពារព្រមទាំងដាំឡើងវិញរួមមានៈ ត្រែង រៃ គ្រស់ រាំង ទន្លា | ៣០០ | អង្គការដៃគូ រដ្ឋបាលជលផល | កក្កដា ២០១៩ | មិថុនា ២០២២ | |
| ឃ.២. គាំទ្រជីវភាពប្រជាពលរដ្ឋ | | | | | | | |
| ឃ.២.១. ផែនការមុខរបរបង្កើនប្រាក់ចំណូល | ចិញ្ចឹមគោតាមបច្ចេកទេសជាលក្ខណៈគ្រួសារ | ៤០ គ្រួសារចេះបច្ចេកទេសចិញ្ចឹមគោ និងអាចលក់រកប្រាក់ចំណូលបន្ថែម | ៣០.០០០ | អង្គការដៃគូ រដ្ឋបាលជលផល | កក្កដា ២០១៩ | មិថុនា ២០២២ | |
| | ចិញ្ចឹមក្របីតាមបច្ចេកទេសជាលក្ខណៈគ្រួសារ | ២០ គ្រួសារចេះបច្ចេកទេសចិញ្ចឹមក្របី និងអាចលក់រកប្រាក់ចំណូលបន្ថែម | ១៦.០០០ | | កក្កដា ២០១៩ | មិថុនា ២០២២ | |
| | ចិញ្ចឹមទាកាប និងទាកាប៉ាតាមបច្ចេកទេសជាលក្ខណៈគ្រួសារ | ២០ គ្រួសារចេះបច្ចេកទេសចិញ្ចឹមទាកាប៉ា និងអាចលក់រកប្រាក់ចំណូលបន្ថែម | ៤.០០០ | | កក្កដា ២០១៩ | មិថុនា ២០២២ | |
| | ចិញ្ចឹមជ្រូកតាមបច្ចេកទេសជាលក្ខណៈគ្រួសារ | ២០ គ្រួសារចេះបច្ចេកទេសចិញ្ចឹមជ្រូក និងអាចលក់រកប្រាក់ចំណូលបន្ថែម | ៣.០០០ | | កក្កដា ២០១៩ | មិថុនា ២០២២ | |
| | បណ្តុះផ្សិត | ៥ គ្រួសារចេះបច្ចេកទេសបណ្តុះផ្សិត និងអាចលក់រកប្រាក់ចំណូលបន្ថែម | ៥០០ | | កក្កដា ២០១៩ | មិថុនា ២០២២ | |
| ឃ.២.២. ផែនការអភិវឌ្ឍន៍វារីវប្បកម្ម | ចិញ្ចឹមត្រីអណ្តែងក្នុងអាងតាមបច្ចេកទេសជាលក្ខណៈគ្រួសារ (អាងស៊ីម៉ង់ ទំហំ ៦មx៦ម) | ៥ គ្រួសារចេះបច្ចេកទេសចិញ្ចឹមត្រីអណ្តែង និងអាចលក់រកប្រាក់ចំណូលបន្ថែម | ១០.០០០ | អង្គការដៃគូ រដ្ឋបាលជលផល | កក្កដា ២០១៩ | មិថុនា ២០២២ | |

| ប្រភេទផែនការ | សកម្មភាព | លទ្ធផលរំពឹងទុក | ការប៉ាន់ស្មានថវិកា(ដុល្លារ) | ប្រភពថវិកា | ពេលចាប់ផ្តើម | ពេលបញ្ចប់ | ផ្សេងៗ (ដុល្លារ) |
|---|---|---|---|---|---|---|---|
| ឃ.២.៣. ផែនការរៀបចំ និងពង្រឹងក្រុមសន្សំប្រាក់ | បង្កើត និងពង្រឹងក្រុមសន្សំប្រាក់ | ក្រុមសន្សំប្រាក់ថ្មី១ក្រុមត្រូវបានបង្កើត និង១ក្រុមចាស់ត្រូវបានពង្រឹង | ៤០០ | អង្គការដៃគូ រដ្ឋបាលជលផល | កក្កដា ២០១៩ | មិថុនា ២០២២ | |
| ឃ.២.៤. ផែនការសេវាសហគមន៍ និងហេដ្ឋារចនាសម្ព័ន្ធ | ជួសជុលស្ពានឈើក្នុងភូមិ | ស្ពានឈើប្រវែង១៥ម៉ែត្រត្រូវបានជួសជុល ដើម្បីបំរើជាប្រយោជន៍រួមរបស់សហគមន៍ | ៧.៥០០ | អង្គការដៃគូ រដ្ឋបាលជលផល | កក្កដា ២០១៩ | មិថុនា ២០២២ | |
| | សាងសង់លូបង្ហូរទឹកកាត់ផ្លូវ និងចាក់ដីលើលូ | លូបង្ហូរទឹក២កន្លែងត្រូវបានដាក់ និងប្រើជាប្រយោជន៍រួមរបស់សហគមន៍ | ៧.០០០ | | កក្កដា ២០១៩ | មិថុនា ២០២២ | |
| | ជួសជុលផ្លូវលំក្នុងភូមិ | ផ្លូវលំក្នុងភូមិប្រវែង១,៥គីឡូម៉ែត្រត្រូវបានជួសជុល ដើម្បីបំរើជាប្រយោជន៍រួមរបស់សហគមន៍ | ១៥.០០០ | | កក្កដា ២០១៩ | មិថុនា ២០២២ | |
| | សាងសង់បង្គន់អនាម័យបន្ថែម | ៥០ បង្គន់ត្រូវបានសាងសង់ និងប្រើប្រាស់ជាប្រយោជន៍របស់គ្រួសារសមាជិកសហគមន៍ | ១០.០០០ | | កក្កដា ២០១៩ | មិថុនា ២០២២ | |
| ឃ.២.៥. ផែនការពង្រឹងសកម្មភាពសហគមន៍នេសាទទេសចរណ៍ធម្មជាតិ | សិក្សាកន្លែងដែលអាចបង្កើតជាតំបន់សហគមន៍នេសាទទេសចរណ៍ធម្មជាតិគឺអន្លង់ត្រែងនិងក្បាលកោះជ្រើម | តំបន់សក្តានុពលទេសចរណ៍ធម្មជាតិត្រូវបានសិក្សា និងរៀបចំ | ២០០ | អង្គការដៃគូ រដ្ឋបាលជលផល | កក្កដា ២០១៩ | ធ្នូ ២០១៩ | |
| | រៀបចំវគ្គបណ្តុះបណ្តាលអំពីបដិសណ្ឋារកិច្ច | ៣វគ្គ (១វគ្គ/១ឆ្នាំ) | ១៥០ | | កក្កដា ២០១៩ | មិថុនា ២០២២ | |



th

| ប្រភេទផែនការ | សកម្មភាព | លទ្ធផលរំពឹងទុក | ការប៉ាន់ស្មានថវិកា(ដុល្លារ) | ប្រភពថវិកា | ពេលចាប់ផ្តើម | ពេលបញ្ចប់ | ផ្សេងៗ (ដុល្លារ) |
|---|---|---|---|---|---|---|---|
| | តម្លើងផ្ទាំងផ្សព្វផ្សាយសកម្មភាពសហគមន៍នេសាទទេសចរណ៍ធម្មជាតិ | ១ផ្ទាំង | ៣០០ | | មករា ២០២០ | មករា ២០២០ | |
| ឃ.៣. ការគ្រប់គ្រង | | | | | | | |
| ឃ.៣.១. ផែនការសកម្មភាពចុះល្បាតទប់ស្កាត់បទល្មើស | សហគមន៍ចុះល្បាតដោយខ្លួនឯង (រដូវវស្សា) | ៤ដង/ខែ | ៣.៦០០ | អង្គការដៃគូ រដ្ឋបាលជលផល | កក្កដា ២០១៩ | មិថុនា ២០២២ | |
| | ចុះល្បាតដោយសហការជាមួយអាជ្ញាធរមូលដ្ឋានដើម្បីទប់ស្កាត់បទល្មើសមកពីក្រៅ (រដូវប្រាំង) | ៤ដង/១ខែ | ៣.៦០០ | | វិច្ឆិកា ២០១៩ | មេសា ២០២២ | |
| | ផ្តល់សម្ភារល្បាត | ១ឈុត | ១.០០០ | | កក្កដា ២០១៩ | កញ្ញា ២០១៩ | |
| | ទិញទូកស្ទាច់ និងម៉ាស៊ីន | ២គ្រឿង (១តូច ១ធំ) | ៣.០០០ | | កក្កដា ២០១៩ | កញ្ញា ២០១៩ | |
| | ប្រេងសម្រាប់ល្បាត | ១២០លីត្រ/១ខែ | ៤.៣២០ | | តុលា ២០១៩ | មិថុនា ២០២២ | |
| | សេវាជួសជុលនិងថែទាំទូក និងម៉ាស៊ីន | ២ដង/ឆ្នាំ | ៦០០ | | តុលា ២០១៩ | មិថុនា ២០២២ | |
| | សាងសង់ទីស្នាក់ការសហគមន៍ | ស្នាក់ការចំនួន១ត្រូវបានសាងសង់ | ៣.០០០ | | កក្កដា ២០១៩ | កញ្ញា ២០១៩ | |
| ឃ.៣.២. ផែនការពង្រឹងគណៈកម្មការសហគមន៍នេសាទ | ប្រជុំប្រចាំខែរបស់គណៈកម្មការសហគមន៍នេសាទ | ១ដង/១ខែ | ៣៦០ | អង្គការដៃគូ រដ្ឋបាលជលផល សហគមន៍នេសាទ | កក្កដា ២០១៩ | មិថុនា ២០២២ | ប្រជុំរៀងរាល់ខែ |
| | ចូលរួមប្រជុំប្រចាំខែជាមួយក្រុមប្រឹក្សាឃុំ | ១ដង/១ខែ | ៣៦០ | | កក្កដា ២០១៩ | មិថុនា ២០២២ | ប្រជុំរៀងរាល់ខែ |
| | បណ្តុះបណ្តាលអំពីរបៀបធ្វើ | ១វគ្គ/១ឆ្នាំ | ៦០ | | កក្កដា ២០១៩ | មិថុនា ២០២២ | |

th

| ប្រភេទផែនការ | សកម្មភាព | លទ្ធផលរំពឹងទុក | ការប៉ាន់ស្មានថវិកា(ដុល្លារ) | ប្រភពថវិកា | ពេលចាប់ផ្តើម | ពេលបញ្ចប់ | ផ្សេងៗ(ដុល្លារ) |
|---|---|---|---|---|---|---|---|
| | កំណត់ហេតុ សរសេរលិខិតរដ្ឋបាល របាយការណ៍ និងរៀបចំទុកឯកសារ | | | | | | |
| | បណ្តុះបណ្តាលអំពីការដោះស្រាយទំនាស់ | ១វគ្គ/១ឆ្នាំ | ៦០ | | កក្កដា ២០១៩ | មិថុនា ២០២២ | |
| | បណ្តុះបណ្តាលអំពីភាពជាអ្នកដឹកនាំ | ១វគ្គ/១ឆ្នាំ | ៦០ | | កក្កដា ២០១៩ | មិថុនា ២០២២ | |
| | បណ្តុះបណ្តាលអំពីការរៀបចំផែនការសកម្មភាពការងារ | ១វគ្គ/១ឆ្នាំ | ៦០ | | កក្កដា ២០១៩ | មិថុនា ២០២២ | |
| | បណ្តុះបណ្តាលអំពីការកត់ត្រាចំណាយចំណូល | ១វគ្គ/១ឆ្នាំ | ៦០ | | កក្កដា ២០១៩ | មិថុនា ២០២២ | |
| | បណ្តុះបណ្តាលអំពីការសរសេរសំណើថវិកា | ១វគ្គ/១ឆ្នាំ | ៦០ | | កក្កដា ២០១៩ | មិថុនា ២០២២ | |
| ឃ.៣.៣. ផែនការបង្កើនការយល់ដឹងដល់សមាជិកសហគមន៍នេសាទ | ផ្សព្វផ្សាយលក្ខន្តិកៈ និងបទបញ្ជាផ្ទៃក្នុងសហគមន៍នេសាទ | ២ដង/ឆ្នាំ | ១៥០ | អង្គការដៃគូ រដ្ឋបាលជលផល សហគមន៍នេសាទ | កក្កដា ២០១៩ | មិថុនា ២០២២ | |
| | ផ្សព្វផ្សាយកិច្ចព្រមព្រៀងកន្លែងនេសាទសហគមន៍ | ១ដង/ឆ្នាំ | ៧៥ | | កក្កដា ២០១៩ | មិថុនា ២០២២ | |
| | ផ្សព្វផ្សាយដែននេសាទនិងកន្លែងអភិរក្សរបស់សហគមន៍ | ១ដង/ឆ្នាំ | ៧៥ | | កក្កដា ២០១៩ | មិថុនា ២០២២ | |
| | ផ្សព្វផ្សាយពីការប្រមូលប្រាក់បដិភាគ | ១ដង/ឆ្នាំ | ៣០ | | កក្កដា ២០១៩ | មិថុនា ២០២២ | |
| | ផ្សព្វផ្សាយច្បាប់ជលផល និងបទដ្ឋានគតិយុត្តិពាក់ព័ន្ធ | ១ដង/ឆ្នាំ | ៧៥ | | កក្កដា ២០១៩ | មិថុនា ២០២២ | |
| | យុទ្ធនាការផ្សព្វផ្សាយការយល់ដឹងអំពីសារប្រយោជន៍ធនធានជលផល | ១ដង/ឆ្នាំ | ៣០០ | | កក្កដា ២០១៩ | មិថុនា ២០២២ | |
| | ប្រជុំផ្សព្វផ្សាយអំពីតួនាទីរបស់បុរសស្រ្តីក្នុងសហគមន៍នេសាទ និងការងារ | ១ដង/ឆ្នាំ | ៧៥ | | កក្កដា ២០១៩ | មិថុនា ២០២២ | |

| ប្រភេទផែនការ | សកម្មភាព | លទ្ធផលរំពឹងទុក | ការប៉ាន់ស្មានថវិកា(ដុល្លារ) | ប្រភពថវិកា | ពេលចាប់ផ្តើម | ពេលបញ្ចប់ | ផ្សេងៗ (ដុល្លារ) |
|---|---|---|---|---|---|---|---|
| | ផ្ទះ សមភាពនិងសមធម៌យេនឌ័រ | | | | | | |
| ឃ.៣.៤. ការផ្សព្វផ្សាយផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍ | ផ្សព្វផ្សាយផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍ទៅសមាជិកសហគមន៍តាមរយៈបុណ្យទាន មហាសន្និបាតប្រចាំឆ្នាំ | ១ដង/ឆ្នាំ | ១៥០ | អង្គការដៃគូ រដ្ឋបាលជលផល គណៈកម្មការសហគមន៍នេសាទ | កក្កដា ២០១៩ | មិថុនា ២០២២ | |
| | បញ្ចូលផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍ទៅក្នុងកម្មវិធីវិនិយោគឃុំ | ១ដង/ឆ្នាំ | ៣០ | | កក្កដា ២០១៩ | មិថុនា ២០២២ | |
| ឃ.៣.៥. ផែនការថវិកាទ្រទ្រង់សម្រាប់អភិវឌ្ឍន៍សហគមន៍ | ភាគទានពីសមាជិកសហគមន៍ | សមាជិកសហគមន៍បង់ប្រាក់សមាជិកភាព | ១៨១,២៥ | ថវិកាសហគមន៍ | កក្កដា ២០១៩ | មិថុនា ២០២២ | |
| | ភាគទានប្រចាំឆ្នាំ | គ្រួសារជាសមាជិកសហគមន៍នេសាទបង់ភាគទានប្រចាំឆ្នាំទៀងទាត់រៀងរាល់ឆ្នាំ | ៨៦,៦៣ | | កក្កដា ២០១៩ | មិថុនា ២០២២ | |
| | ប្រាក់ចំណូលពីប្រភពផ្សេងៗ (អំណោយពីរាជរដ្ឋាភិបាល អំណោយពីសប្បុរសជន ជំនួយពីអង្គការជាតិ និងអង្គការដៃគូនានា) | សហគមន៍នេសាទទទួលបានកញ្ចប់ថវិកាពីប្រភពផ្សេងៗ | ១៣០.៨៣៥,៦ | អង្គការដៃគូ រដ្ឋបាលជលផល | កក្កដា ២០១៩ | មិថុនា ២០២២ | |
| ង. ការតាមដាន ត្រួតពិនិត្យ និងវាយតម្លៃ | ប្រជុំផ្ទៃក្នុង ប្រចាំត្រីមាសរបស់គណៈកម្មការសហគមន៍នេសាទ | ៤ដង/ឆ្នាំ | ១២០ | អង្គការដៃគូ រដ្ឋបាលជលផល | កក្កដា ២០១៩ | មិថុនា ២០២២ | |
| | រៀបចំមហាសន្និបាតសហគមន៍ប្រចាំឆ្នាំ ដោយមានការចូលរួមពី ស្ត្រីជនជាតិដើមភាគតិច និងជនជាតិភាគតិច | ១ដង/ឆ្នាំ | ៦០០ | គណៈកម្មការសហគមន៍នេសាទ | កក្កដា ២០១៩ | មិថុនា ២០២២ | |

សម្គាល់៖ សហគមន៍នេសាទនៅខេត្តក្រចេះនិងស្ទឹងត្រែងដែលគម្រោងគាំទ្របានចាប់ផ្តើមរៀបចំផែនការគ្រប់គ្រងនៅត្រីមាសទី៤ឆ្នាំ២០១៨។

# តារាងកម្មវិធីការងារប្រចាំឆ្នាំ ( កក្កដា ២០១៩ - មិថុនា ២០២២ )

| សកម្មភាព | ពេលវេលា | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | ២០១៩ | | | | | | ២០២០ | | | | | | | | | | | | ២០២១ | | | | | | | | | | | | ២០២២ | | | | | |
| | ៧ | ៨ | ៩ | ១០ | ១១ | ១២ | ១ | ២ | ៣ | ៤ | ៥ | ៦ | ៧ | ៨ | ៩ | ១០ | ១១ | ១២ | ១ | ២ | ៣ | ៤ | ៥ | ៦ | ៧ | ៨ | ៩ | ១០ | ១១ | ១២ | ១ | ២ | ៣ | ៤ | ៥ | ៦ |
| **យ.១. ធនធានជលផល និងអេកូឡូស៊ី** | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | |
| **យ.១.១. ផែនការប្រើប្រាស់ឧបករណ៍នេសាទ** | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | |
| ផ្សព្វផ្សាយពីប្រភេទឧបករណ៍នេសាទដែលអនុញ្ញាត និងហាមឃាត់ | | | | | X | | | | | X | | | | | | | X | | | | | X | | | | | | | X | | | | | X | | |
| **យ.១.២. ផែនការកំណត់ និងរៀបចំកន្លែងអភិរក្សសហគមន៍** | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | |
| ដាក់ពោង និងស្លាកសញ្ញាសំគាល់កន្លែងអភិរក្ស | X | X | X | X | X | X | | | | | | | | | | | | | | | | | | | | | | | | | | | | | | |
| តម្លើងផ្ទាំងផ្សព្វផ្សាយអំពីច្បាប់ជលផល និងការអភិរក្ស | X | X | X | X | X | X | | | | | | | | | | | | | | | | | | | | | | | | | | | | | | |
| លែងកូនត្រីពូជ | X | | | | | | | | | | | | X | | | | | | | | | | | | X | | | | | | | | | | | |
| **យ.១.៣. ផែនការបោះបង្គោលព្រំប្រទល់ និងផ្ទាំងប៉ាណូផែនទីកន្លែងនេសាទសហគមន៍** | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | |
| បោះបង្គោលព្រំលើគោក និងដាក់ពោងក្នុងទឹក | X | X | X | X | X | X | | | | | | | | | | | | | | | | | | | | | | | | | | | | | | |
| រៀបចំ និងលើកផ្ទាំងប៉ាណូផែនទីកន្លែងនេសាទសហគមន៍ | | | | X | X | X | | | | | | | | | | | | | | | | | | | | | | | | | | | | | | |
| **យ.១.៤. ផែនការគ្រប់គ្រងព្រៃលិចទឹក** | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | |
| ដាំព្រៃលិចទឹក | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X |
| **យ.២. គាំទ្រជីវភាពប្រជាពលរដ្ឋ** | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | |
| **យ.២.១. ផែនការមុខរបរបង្កើនប្រាក់ចំណូល** | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | |

th

| សកម្មភាព | ពេលវេលា | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | ២០១៩ | | | | | | ២០២០ | | | | | | | | | | | | ២០២១ | | | | | | | | | | | | ២០២២ | | | | | |
| | ៧ | ៨ | ៩ | ១០ | ១១ | ១២ | ១ | ២ | ៣ | ៤ | ៥ | ៦ | ៧ | ៨ | ៩ | ១០ | ១១ | ១២ | ១ | ២ | ៣ | ៤ | ៥ | ៦ | ៧ | ៨ | ៩ | ១០ | ១១ | ១២ | ១ | ២ | ៣ | ៤ | ៥ | ៦ |
| ចិញ្ចឹមគោជាលក្ខណៈគ្រួសារ | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X |
| ចិញ្ចឹមក្របីជាលក្ខណៈគ្រួសារ | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X |
| ចិញ្ចឹមទាកាប និងទាកាប៉ាជាលក្ខណៈគ្រួសារ | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X |
| ចិញ្ចឹមជ្រូកជាលក្ខណៈគ្រួសារ | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X |
| បណ្តុះផ្សិត | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X |
| ឃ.២.២. ផែនការអភិវឌ្ឍន៍វារីវប្បកម្ម | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | |
| ចិញ្ចឹមត្រីអណ្តែងក្នុងរោង | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X |
| ឃ.២.៣. ផែនការរៀបចំ និងពង្រឹងក្រុមសន្សំប្រាក់ | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | |
| បង្កើត និងពង្រឹងក្រុមសន្សំប្រាក់ទាំងថ្មីនិងចាស់២ក្រុម | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X |
| ឃ.២.៤. ផែនការសេវាសហគមន៍ និងហេដ្ឋារចនាសម្ព័ន្ធ | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | |
| ជួសជុលស្ពានឈើក្នុងភូមិ | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X |
| សាងសង់លូបង្ហូរទឹកកាត់ផ្លូវ | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X |
| ជួសជុលផ្លូវលំក្នុងភូមិ | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X |
| សាងសង់បង្គន់អនាម័យបន្ថែម | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X |
| ឃ.២.៥. ផែនការពង្រឹងសកម្មភាពសហគមន៍នេសាទទេសចរណ៍ធម្មជាតិ | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | |
| សិក្សាកន្លែងដែលអាចបង្កើតជាតំបន់សហគមន៍នេសាទទេសចរណ៍ធម្មជាតិគឺ អន្លង់ក្រែង និង ក្បាលកោះជ្រឹម | X | X | X | X | X | X | | | | | | | | | | | | | | | | | | | | | | | | | | | | | | |
| រៀបចំវគ្គបណ្តុះបណ្តាលអំពី | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X |

| សកម្មភាព | ពេលវេលា | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | ២០១៩ | | | | | | ២០២០ | | | | | | | | | | | | ២០២១ | | | | | | | | | | | | ២០២២ | | | | | |
| | ៧ | ៨ | ៩ | ១០ | ១១ | ១២ | ១ | ២ | ៣ | ៤ | ៥ | ៦ | ៧ | ៨ | ៩ | ១០ | ១១ | ១២ | ១ | ២ | ៣ | ៤ | ៥ | ៦ | ៧ | ៨ | ៩ | ១០ | ១១ | ១២ | ១ | ២ | ៣ | ៤ | ៥ | ៦ |
| បដិសណ្ឋារកិច្ច | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | |
| តម្លើងផ្ទាំងផ្សព្វផ្សាយសកម្មភាពសហគមន៍នេសាទទេសចរណ៍ធម្មជាតិ | | | | | | | X | | | | | | | | | | | | | | | | | | | | | | | | | | | | | |
| **ឃ.៣. ការគ្រប់គ្រង** | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | |
| **ឃ.៣.១. ផែនការសកម្មភាពចុះល្បាតទប់ស្កាត់បទល្មើស** | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | |
| សហគមន៍ចុះល្បាតដោយខ្លួនឯង (រដូវវស្សា) | X | X | X | X | | | | | | | X | X | X | X | X | X | | | | | | | X | X | X | X | X | X | | | | | | | X | X |
| ចុះល្បាតដោយសហការជាមួយអាជ្ញាធរមូលដ្ឋានដើម្បីទប់ស្កាត់បទល្មើសមកពីក្រៅ (រដូវប្រាំង) | | | | | X | X | X | X | X | X | | | | | | | X | X | X | X | X | X | | | | | | | X | X | X | X | X | X | | |
| ផ្តល់សម្ភារល្បាត | X | X | X | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | |
| ទិញទូកស្មាច់ និងម៉ាស៊ីន | X | X | X | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | |
| ប្រេងសម្រាប់ល្បាត | | | | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X |
| សេវាជួសជុលនិងថែទាំទូកនិងម៉ាស៊ីន | | | | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X |
| សាងសង់ទីស្នាក់ការសហគមន៍ | X | X | X | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | |
| **ឃ.៣.២. ផែនការពង្រឹងគណៈកម្មការសហគមន៍នេសាទ** | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | |
| ប្រជុំប្រចាំខែរបស់គណៈកម្មការសហគមន៍នេសាទ | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X |
| ចូលរួមប្រជុំប្រចាំខែជាមួយ | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X |

th

| សកម្មភាព | ពេលវេលា | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | ២០១៩ | | | | | | ២០២០ | | | | | | | | | | | | ២០២១ | | | | | | | | | | | | ២០២២ | | | | | |
| | ៧ | ៨ | ៩ | ១០ | ១១ | ១២ | ១ | ២ | ៣ | ៤ | ៥ | ៦ | ៧ | ៨ | ៩ | ១០ | ១១ | ១២ | ១ | ២ | ៣ | ៤ | ៥ | ៦ | ៧ | ៨ | ៩ | ១០ | ១១ | ១២ | ១ | ២ | ៣ | ៤ | ៥ | ៦ |
| ក្រុមប្រឹក្សាឃុំ | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | |
| បណ្តុះបណ្តាលអំពីរបៀបធ្វើកំណត់ហេតុ សរសេរលិខិតរដ្ឋបាល របាយការណ៍ និងរៀបចំទុកដាក់ឯកសារ | | | | | | | | | | | | X | | | | | | | | | | | | X | | | | | | | | | | | | X |
| បណ្តុះបណ្តាលអំពីការដោះស្រាយទំនាស់ | | | X | | | | | | | | | | | | X | | | | | | | | | | | | X | | | | | | | | | |
| បណ្តុះបណ្តាលអំពីភាពជាអ្នកដឹកនាំ | | | | | X | | | | | | | | | | | X | | | | | | | | | | | | X | | | | | | | | |
| បណ្តុះបណ្តាលអំពីការរៀបចំផែនការសកម្មភាពការងារ | | | | | | X | | | | | | | | | | | X | | | | | | | | | | | | X | | | | | | | |
| បណ្តុះបណ្តាលអំពីការកត់ត្រាចំណាយចំណូល | | | | | | | X | | | | | | | | | | | X | | | | | | | | | | | | X | | | | | | |
| បណ្តុះបណ្តាលអំពីការសរសេរសំណើថវិកា | | | | | | | | X | | | | | | | | | | | X | | | | | | | | | | | | X | | | | | |
| ឃ.៣.៣. ផែនការបង្កើនការយល់ដឹងដល់សមាជិកសហគមន៍នេសាទ | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | |
| ផ្សព្វផ្សាយលក្ខន្តិកៈ និងបទបញ្ជាផ្ទៃក្នុងសហគមន៍នេសាទ | | X | | | | | | | | | X | | | X | | | | | | | | | X | | | X | | | | | | | | | X | |
| ផ្សព្វផ្សាយកិច្ចព្រមព្រៀងកន្លែងនេសាទសហគមន៍ | | X | | | | | | | | | | | | X | | | | | | | | | | | | X | | | | | | | | | | |
| ផ្សព្វផ្សាយដែននេសាទនិងកន្លែងអភិរក្សរបស់សហគមន៍ | | X | | | | | | | | | | | | X | | | | | | | | | | | | X | | | | | | | | | | |

| សកម្មភាព | ពេលវេលា | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | ២០១៩ | | | | | | ២០២០ | | | | | | | | | | | | ២០២១ | | | | | | | | | | | | ២០២២ | | | | | |
| | ៧ | ៨ | ៩ | ១០ | ១១ | ១២ | ១ | ២ | ៣ | ៤ | ៥ | ៦ | ៧ | ៨ | ៩ | ១០ | ១១ | ១២ | ១ | ២ | ៣ | ៤ | ៥ | ៦ | ៧ | ៨ | ៩ | ១០ | ១១ | ១២ | ១ | ២ | ៣ | ៤ | ៥ | ៦ |
| ផ្សព្វផ្សាយពីការប្រមូលប្រាក់សមាជិកភាព និងភាគទានប្រចាំឆ្នាំ | | | | | | | | X | | | | | | | | | | | | X | | | | | | | | | | | | X | | | | |
| ផ្សព្វផ្សាយច្បាប់ជលផល និងលិខិតបទដ្ឋានគតិយុត្តិពាក់ព័ន្ធ | | | X | | | | | | | | | | | | X | | | | | | | | | | | | X | | | | | | | | | |
| យុទ្ធនាការផ្សព្វផ្សាយការយល់ដឹងអំពីសារប្រយោជន៍ធនធានជលផល | | X | | | | | | | | | | | | X | | | | | | | | | | | | X | | | | | | | | | | |
| ប្រជុំផ្សព្វផ្សាយអំពីតួនាទីរបស់បុរស-ស្ត្រីក្នុងសហគមន៍នេសាទសមភាពនិងសមធម៌យេនឌ័រ | | | | X | | | | | | | | | | | | X | | | | | | | | | | | | X | | | | | | | | |
| ឃ.៣.៤. ការផ្សព្វផ្សាយផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍ | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | |
| ផ្សព្វផ្សាយផែនការគ្រប់គ្រង | | | | | | X | | | | | | | | | | | | X | | | | | | | | | | | | X | | | | | | X |
| បញ្ចូលផែនការគ្រប់គ្រងទៅក្នុងកម្មវិធីវិនិយោគឃុំ | X | X | | | | | | | | | | | X | X | | | | | | | | | | | X | X | | | | | | | | | | |
| ឃ.៣.៥. ផែនការថវិកាទ្រទ្រង់សម្រាប់អភិវឌ្ឍន៍សហគមន៍ | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | |
| ភាគទានពីសមាជិកសហគមន៍ | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X |
| ភាគទានប្រចាំឆ្នាំ | | | | | | | | X | | | | | | | | | | | | X | | | | | | | | | | | | X | | | | |
| ប្រាក់ចំណូលពីប្រភពផ្សេងៗ | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X | X |
| ង. ការតាមដាន ត្រួតពិនិត្យ និងវាយតម្លៃ | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | |
| ប្រជុំផ្ទៃក្នុងប្រចាំត្រីមាសរបស់គណៈកម្មការសហគមន៍នេសាទ | | | X | | | X | | | X | | | X | | | X | | | X | | | X | | | X | | | X | | | X | | | X | | | X |

| សកម្មភាព | ពេលវេលា | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | ២០១៩ | | | | | | ២០២០ | | | | | | | | | | | | ២០២១ | | | | | | | | | | | | ២០២២ | | | | | |
| | ៧ | ៨ | ៩ | ១០ | ១១ | ១២ | ១ | ២ | ៣ | ៤ | ៥ | ៦ | ៧ | ៨ | ៩ | ១០ | ១១ | ១២ | ១ | ២ | ៣ | ៤ | ៥ | ៦ | ៧ | ៨ | ៩ | ១០ | ១១ | ១២ | ១ | ២ | ៣ | ៤ | ៥ | ៦ |
| រៀបចំមហាសន្និបាតសហគមន៍ប្រចាំឆ្នាំ ដោយមានការចូលរួមពីស្ត្រី ជនជាតិដើមភាគតិច និងជនជាតិភាគតិច | | | | | | X | | | | | | | | | | | | X | | | | | | | | | | | | X | | | | | | |

សូមគោរពជូន
លោកមេឃុំអូរគ្រៀង
"ដើម្បីជូនពិនិត្យ និងសម្រួល"
ថ្ងៃ ៦ ១៣ ខែភទ្របទ ឆ្នាំកុរ ឯកស័ក ព.ស.២៥៦៣
ខ្សាច់លាវ ថ្ងៃទី២៤ ខែ កក្កដា ឆ្នាំ២០១៩
ប្រធានគណៈកម្មការសហគមន៍នេសាទភូមិខ្សាច់លាវ

ហុម ស៊ីន

លេខ : ៤១២/ឃអគ
បានឃើញ និងគោរពជូន
លោកនាយសង្កាត់រដ្ឋបាលជលផលសំបូរ
"ដើម្បីជូនពិនិត្យ និងសម្រួល"
ថ្ងៃ ៦ ១៣ ខែភទ្របទ ឆ្នាំកុរ ឯកស័ក ព.ស.២៥៦៣
ឃុំអូរគ្រៀង ថ្ងៃទី ២៦ ខែ កក្កដា ឆ្នាំ២០១៩
មេឃុំអូរគ្រៀង

កែវ_បុប្ផា

លេខ : ១៦ ស.រ.ជ.ស.ប
បានឃើញ និងគោរពជូន
លោកនាយផ្នែករដ្ឋបាលជលផលកាំពី
"ដើម្បីជូនពិនិត្យ និងសម្រួល"
ថ្ងៃ ៧ ១៤ ខែភទ្របទ ឆ្នាំកុរ ឯកស័ក ព.ស.២៥៦៣
សំបូរ ថ្ងៃទី ២៤ ខែ កក្កដា ឆ្នាំ២០១៩
នាយសង្កាត់រដ្ឋបាលជលផលសំបូរ

ស៊ុំ ចាន់ស៊ូ

លេខ : ០៣៤ ក.រ.ក.៣

បានឃើញ និងគោរពជូន

លោកនាយខណ្ឌរដ្ឋបាលជលផលក្រចេះ

"ដើម្បីជូនពិនិត្យ និងសម្រួល"

ថ្ងៃ...... ខែ...... ឆ្នាំកុរ ឯកស័ក ព.ស.២៥៦៣

កាំពី ថ្ងៃទី ២៦ ខែ កក្កដា ឆ្នាំ២០១៩

ស.នាយផ្នែករដ្ឋបាលជលផលកាំពី

ភិរុ សុវណ្ណារី

លេខ : ១៥៧ ក.រ.ក្រច

បានឃើញ និងគោរពជូន

លោកប្រធាន

មន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទខេត្តក្រចេះ

"ដើម្បីជូនពិនិត្យ និងសម្រួល"

ថ្ងៃ...... ខែ...... ឆ្នាំកុរ ឯកស័ក ព.ស.២៥៦៣

ក្រចេះ ថ្ងៃទី ២៦ ខែ កក្កដា ឆ្នាំ២០១៩

នាយខណ្ឌរដ្ឋបាលជលផលក្រចេះ

ឡៀន គិន

លេខ : ២១៣ កសរន-ក្រច

បានឃើញ និងគោរពជូន

ឯកឧត្តមប្រតិភូរាជរដ្ឋាភិបាលកម្ពុជា ទទួលបន្ទុកជា

ប្រធានរដ្ឋបាលជលផល

"ដើម្បីជូនពិនិត្យ និងសម្រេចដោយអនុគ្រោះ"

ថ្ងៃ...... ខែ...... ឆ្នាំកុរ ឯកស័ក ព.ស.២៥៦៣

ក្រចេះ ថ្ងៃទី ៣១ ខែ កក្កដា ឆ្នាំ២០១៩

ប្រធាន

មន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទខេត្តក្រចេះ

ថ្រី សុភក្តិ

លេខ : ១០៣

បានឃើញ និងឯកភាព

ថ្ងៃ...... ខែ...... ឆ្នាំកុរ ឯកស័ក ព.ស.២៥៦៣

រាជធានីភ្នំពេញ ថ្ងៃទី ៣១ ខែ កក្កដា ឆ្នាំ២០១៩

**ប្រតិភូរាជរដ្ឋាភិបាលកម្ពុជា ទទួលបន្ទុកជា**

**ប្រធានរដ្ឋបាលជលផល**

**អេង ជាសាន**